សារព័ត៌មាន ខ្មែរប៉ុស្ដិ៍ ស.រ.អា

# KhmerPost USA

Free Copies

Email:Khmerpostusa@gmail.com
www.khmerpostusa.com

Vol. 15. Issue 364, July 19, 2024 | Direct: 978-656-8141

Lowell - Lynn - Revere - MA * Providence - Cranston - RI

## តើវៀតណាមត្រៀមលក្ខណៈគ្រប់គ្រងភូមិសាស្ត្រនយោបាយនៃប្រជាជាតិអាស៊ីអាគ្នេយ៍ឬ?

ដោយ៖ សុបិន អ៊ុង

ភ្នំពេញ ប្រទេសកម្ពុជា - ថ្មីៗនេះ ប្រធានាធិបតីវៀតណាម លោក តូ ឡាំ បានមកបំពេញទស្សនកិច្ចនៅប្រទេសឡាវ និងកម្ពុជា និងបានជួបជាមួយមេដឹកនាំគណបក្សឡាវនៅថ្ងៃទី ១១ ខែកក្កដា មុនពេលមកដល់ប្រទេសកម្ពុជានៅ

តទៅទំព័រទី០៩

## Is Vietnam Gearing Up For Geopolitical Control of Southeast Asian Nations?

By Soben Ung

Phnom Penh, Cambodia – Vietnamese President To Lam recently visited Laos and Cambodia, and met with the Laotian Party Leader on July 11, prior to arriving in Cambodia on July 12. The President had meetings with Cambodia's King Norodom

Please see /09



Vietnamese President Meets Cambodian People's Party President Hun Sen in Phnom Penh, July 12, 2024

## កម្ពុជាចាប់សកម្មជនមាតាធម្មជាតិ ១០ នាក់ ដាក់ពន្ធនាគារពីបទ "ក្បត់ជាតិ"

ដោយ៖ សុបិន អ៊ុង

ថ្ងៃទី ២ ខែកក្កដា – តុលាការក្រុងភ្នំពេញបានកាត់ទោសសកម្មជនបរិស្ថានចំនួន ១០ នាក់ ជាក្រុមយុវជនទទួលបានពានរង្វាន់ ក្រុមយុវជនដែល

តទៅទំព័រទី០៥

## Cambodia Jailed Ten Mother Nature Activists for "Plotting Against the State"

Please see /05




### ជំនន់ទឹកភ្លៀងនៅរាជធានីភ្នំពេញ នៅតែជាបញ្ហាដដែលៗ

ទឹកជំនន់លាយឡំនឹងទឹកលូកខ្វក់ នៅក្នុងរាជធានីភ្នំពេញ នៅតែជាបញ្ហា

សូមអាននៅទំព័រ ០៨



### ការបែកធ្លាយសារសំឡេងអោយធ្វើទុក្ខបុកម្នេញមកលើសារព័ត៌មាននៅក្រៅប្រទេស

អ្នកឃ្លាំមើលចាត់ទុកសារជំរុញឲ្យកងកម្លាំងប្រដាប់អាវុធ ដែលជាកម្លាំង

សូមអាននៅទំព័រ ២០



### លោក អ៊ុំ សំអាន ទាមទារឱ្យលោក សុខ ឥសាន ចេញមុខសុំទោសពលរដ្ឋខ្មែរក្រោមជាសាធារណៈ

តំណាងរាស្ត្រគណបក្សសង្គ្រោះ

សូមអាននៅទំព័រ ១៦



### ឌណាល ត្រាំ រងការបាញ់ប្រហារនៅវីលរ៉ូគីរដ្ឋផេនស៊ីវេនា

អឺរ៉ុប ថ្ងៃទី១៥កក្កដា២០២៤

សូមអាននៅទំព័រ ២១



# ស្លន់ស្លោនៅពេលបោះឆ្នោតសភាមុនអាណត្តិរបស់ប្រទេសបារាំង

អឺរ៉ុប ថ្ងៃទី ៨កក្កដា ២០២៤

នៅពេលដែលគណបក្សស្តាំផុត (FN Front national)នៅប្រទេសបារាំង បានទទួលលទ្ធផលប្រសើរជាងគណបក្សបារាំងទាំងអស់ នៅពេលបោះឆ្នោតនៅសភាអឺរ៉ុប លោកប្រធានាធិបតី ម៉ាក្រុង បានបង្ហាញភាពឆោឡោ ដោយប្រកាសរំលាយសភាបារាំងមុនអាណត្តិ កាលពីថ្ងៃទី១៩មិថុនា ហើយការបោះឆ្នោតសភាថ្មី ដែលប្រព្រឹត្តទៅ២ដង គឺនៅថ្ងៃទី៣០មិថុនាម្តង នឹងថ្ងៃទី៧កក្កដាជាចុងក្រោយដើម្បីជ្រើសរើសសមាជិកសភាថ្មី ចំនួន៥៧៧នាក់ ឡើងមកវិញ។ ភាពឆោឡោ បានធ្វើឲ្យនយោបាយប្រទេសបារាំងឋិតនៅក្នុងសភាពមិនច្បាស់លាស់ ដោយភាពគ្រោះថ្នាក់ មកពីគណបក្សស្តាំផុតបារាំង អាចនឹងយកសភាបាន ហើយក៏អាចយកប្រធានាធិបតីនៅ៣ឆ្នាំខាងមុខទៀតបានផង, គណបក្ស FN មិនដែលមានប្រវត្តិជាគណបក្សធំរបស់ប្រជាជាតិ ហើយក៏មានឈ្មោះថាជាគណបក្សដែលមានទស្សនៈប្រកាន់ពូជសាស្ត្រ នឹងប្រើអំពើហឹង្សាថែមទៀត។ តើគេឆ្លើយឆ្លាយ៉ាងដូចម្តេច?

នៅពេលមុនបោះឆ្នោតសភា ជុំទី១ គណបក្សទាំងអស់បានរត់ទៅជ្រកតាមសម្ព័ន្ធភាពចំណូលចិត្តតែរៀងខ្លួន គឺទី១ គណបក្សស្តាំផុត FN បានចងសម្ព័ន្ធជាមួយសាធារណរដ្ឋ LR(les republic-ains), បើតាមការស្ទង់មតិថ្មី បានឲ្យពិន្ទុ៣៦%, ទី២ ខាងគណបក្សលោកប្រធានាធិបតី ម៉ាក្រុង ដឹកនាំដោយនាយករដ្ឋមន្ត្រី គ្ហាប្រីយែល អាតាល់ ទៅផ្គាប់គ្នាជាមួយសម្ព័ន្ធភាពដើម្បីសាធារណរដ្ឋ(Rassemblement pour la Republique) គឺប្រមូលសម្ព័ន្ធភាពនៃក្រុមនយោបាយកណ្តាលនិយម មានក្រុម ខ្លះចូលរួម ដែលប្រមូលប្រជាប្រិយភាពបានតែ១៩%តែបារចនាឃោសនាថា«កុំបោះឲ្យខាងស្តាំ ឬក៏ខាងឆ្វេងឲ្យសោះ»ឲ្យអ្នកបោះឆ្នោតធ្វើតាម ...រីឯក្រុមទី៣ គឺសម្ព័ន្ធភាពខាងនយោបានឆ្វេងនិយមធំមួយទៀតនោះឯងមានឈ្មោះថា Front Populaire ដែលដឹកនាំដោយក្រុមកុម្មុយនីស្ត មានក្រុមសង្គមនិយម នឹងពួកបៃតង ចូលរួម មានប្រជាប្រិយភាពរហូតដល់២៩%ឯណោះ គឺមានប្រជាប្រិយភាពលើសក្រុមរដ្ឋាភិបាល


សម្ព័ន្ធភាពពេលបោះឆ្នោតរវាង អេរីក ស្យូទី (គ.LR)តារាជិតរលំនឹង ជ័រដាន់ បាដែឡា(គ.FN)ជាតារាកំពុងរះ នាពេលបោះឆ្នោតសភាអឺរ៉ុប

ទៅទៀត។ តាមច្បាប់បារាំង គណបក្សដែលបានសមាជិកសភាច្រើនជាងគេ គឺជាគណបក្សដែលនឹងរៀបគណរដ្ឋមន្ត្រី


គ្ហាប្រីយែល អាតាល់ នាយករដ្ឋមន្ត្រី នឹង អេម៉ានុយអែល ម៉ាក្រុង ប្រធានាធិបតីប្រទេសបារាំង

ថ្មី របស់ប្រទេសបារាំង ដូច្នេះ គេបារម្ភខ្លាំងណាស់ថាគណបក្សស្តាំផុតនិយមFN ជាអ្នករៀបគណរដ្ឋមន្ត្រីសម្រាប់ប្រទេសបារាំង នៅបន្ទាប់ថ្ងៃទី៨កក្កដា ខាងមុខជាមិនខាន ពេលនោះនយោបាយបារាំងអាចនឹងផ្លាស់ប្តូរខ្វេច ជាលើកដំបូង។

ថ្ងៃទី៣០មិថុនា ជាថ្ងៃបោះឆ្នោតជុំទី១មកដល់ លទ្ធផលនៃសន្លឹកឆ្នោតនោះ បានដូចគ្នានឹងការទាយទុក តាំងពីមុនពេលបោះឆ្នោតមែន, គឺក្រុមស្តាំផុតបានឈ្នះរហូតដល់ទៅ៣៤% ទល់នឹងសម្ព័ន្ធរដ្ឋាភិបាល បានតែ២០%បុណ្ណោះ តិចជាងក្រុមឆ្វេងនិយមនឹងក្រុមកុម្មុយនីស្តទៅទៀត ដែលបាន២៤% ... នាយករដ្ឋមន្ត្រីអាតាល់ នៅលំដាប់ទី៣ ស្លន់ស្លោ ក៏ទៅចងសម្ព័ន្ធភាពជាមួយជាមួយក្រុមសង្គមនិយម នឹងកុម្មុយនិស្តដែលខ្លួនឯងមិនដែលពេញចិត្តពីថ្ងៃមុន ហើយប្តូរពាក្យឃោសនាថ្មីថា«ទប់កុំឲ្យពួក FN យកដំបន់ថ្មីបានសូម្បីតែមួយ», ទៅផ្គាប់ជាមួយសម្ព័ន្ធភាព NFP Nouveau Front populaire នោះហើយដែលនាំគេយល់ថា ការប្រថុយប្រថានរបស់លោកប្រធានាធិបតី ម៉ាក្រុង ក្នុងការសម្រេចរំលាយសភា«ដែលអាចនឹងនាំនូវភាពគ្រោះថ្នាក់ដល់គណបក្សខ្លួនឯង» ពីព្រោះប្រជាពលរដ្ឋជាម្ចាស់ឆ្នោត នៅតែគាំទ្រភាពលេចធ្លោ របស់ក្រុមFN រឹតតែខ្លាំងឡើងដែរ។ ច្បាប់បារាំងបានចែងដែរថា បេក្ខជនណាដែលទទួលបានឆ្នោតលើសពី១២,៥% នឹងចូលប្រកួតជុំទី២ម្តងទៀតបាន ប៉ុន្តែជាទូទៅ មានតែបេក្ខជន២នាក់ប៉ុណ្ណោះ ដែលនៅប្រកួតបន្តរ រីឯករណីឆ្នោតលើសពី១២,៥%លើកនេះ បែរជាអាចមានបេក្ខជន៣នាក់ពេលខ្លះក៏មាន៤នាក់ផងដែរ ដែលទៅប្រកួតជុំទី២បាន... ដូច្នេះនៅតំបន់ខ្លះ បេក្ខជនដែលនៅប្រឈមមុខគ្នា មានដល់ទៅ៣. ៤នាក់ក៏មាន។ ដើម្បីយកឈ្នះលើគូរប្រកួត អ្នកដែលនៅក្នុងសម្ព័ន្ធភាពជាមួយគ្នា ក៏អាចដកបេក្ខភាពចេញពីការប្រគួត ដើម្បីគាំទ្របេក្ខជនជម្រើសគេណាមួយបានដែរ ។ ខាងរដ្ឋាភិបាល គេចងសម្ព័ន្ធជាមួយក្រុមឆ្វេងនិយមគេហៅថា«សម្ព័ន្ធដើម្បីសាធារណរដ្ឋ Le front Republic-ain » ហើយនៅតំបន់ដែលនៅមានបេក្ខជន៣នាក់នៅឡើយ គេណាត់គ្នាថាត្រូវដកបេក្ខជនមួយចេញ ដើម្បីទុកឲ្យអ្នកនៅសល់អាចមានសំណាងយកឈ្នះលើពួកFN បាន... លើកនេះ គេឃើញភាពមិនច្បាស់លាស់ក៏កើតមានម្តងទៀត... ប្រមាណ៣០០ករណី ដែលមានបេក្ខជន៣រូបនៅសល់ក្នុងតំបន់មួយ ដែលមានម្នាក់ត្រូវថយខ្លួន តែក៏មានអ្នកខ្លះ ក៏មិនស្តាប់បង្គាប់មេក្រុមរបស់ខ្លួនដែរ។

ថ្ងៃទី៧កក្កដា បោះឆ្នោតជុំទី២ផ្តាច់

តទៅទំព័រទី០៥






# រញ្ជួយផែនដីនៅគណបក្សប្រជាធិបតេយ្យ បន្ទាប់ពីបេក្ខជនជជែកដេញដោលគ្នា

ពីអឺរ៉ុប ថ្ងៃទី៧ខែ៧ឆ្នាំ២០២៤

បន្ទាប់ពីកិច្ចជជែកដេញដោយរវាងបេក្ខជនប្រធានាធិបតីអាមេរិកកាំង២រូប គឺលោកជោបាយដិនបច្ចុប្បន្នប្រធានាធិបតី នឹងលោកអតីតប្រធានាធិបតី ឌណាល ត្រាំ កាលពីថ្ងៃ..... បានធ្វើឲ្យមានការរំជើបរំជួលខ្លាំងមួយរហូតដល់មានបំណងយ៉ាងសង្វើញ ប្តូរបេក្ខជនខាងគណបក្សប្រធាធិបតេយ្យចេញ ដោយបុព្វហេតុថា«លោកជោ បាយដិន មានវ័យចាស់ជ្រុល(៨១ឆ្នាំ) អាចនឹងពុំមានសមត្ថភាពនៅជាប្រធានាធិបតី ធ្វើការរហូតដល់ចុងបញ្ចប់នៃអាណត្តិរបស់លោកបាន។ លោក បាយដិន បានបង្ហាញឲ្យសាធារណជនឃើញនូវ ស្មារតីភ្លេចភ្លាំងច្រើនដង តទល់នឹងគូរប្រកួត ឌណាល ត្រាំ ដែលអាយុច្រើនប្រហែលគ្នា តែមានកម្លាំងនឹងស្មារតីមាំមួនគ្រាន់បើជាង ហើយចេះតែជេបង្អាប់គូរប្រជែងខ្លួន ឥតឈប់ឈរ។ អ្នកកាសែត«នូយ៉កថែម»នឹងក្រុមអ្នកគាំទ្រគណបក្សប្រជាធិបតេយ្យជាច្រើន បានបញ្ចេញយោបល់ថា«លោក បាយដិន គួរតែដកខ្លួនថយ»ដោយសារសុខភាពមិនគ្រប់គ្រាន់នោះ។

ទោះជាលោក បាយដិន ខិតខំដោះសារថាលោកមិនមានកម្លាំងមាំមួន ពីព្រោះនាពេលនោះ លោកធ្វើការច្រើនពេកក្តី ក៏ភាពរជើបរំជួលមិនបានថមថយទៅវិញទេ លោកបានបន្ទន់ចិត្តអ្នកបោះឆ្នោតទៀតថា«ពុំមាននរណាម្នាក់ អាចយកឈ្នះ ឌណាល ត្រាំ ប្រសើជាងខ្លួនខ្ញុំទេ»ក៏នៅតែមិនគ្រប់គ្រាន់ទៀត។ ភរិយារបស់លោក ជោ គឺ យីលបាយដិន បានគាំទ្រការជជែកដេញដោលថា«ប្តីរបស់គាត់ បានឆ្លើយសំនួរជាច្រើន ហើយនិយាយតែពាក្យពិត រីឯ ឌណាល ត្រាំ វិញនិយាយតែពាក្យកុហករហូតមក», ចូលរួមទាំងអតីតប្រធានាធិបតី បារ៉ាក់ អូបាម៉ា ក៏ជួយលើកទឹកចិត្តលោក បាយដិន ខ្លាំងណាស់ដែរ ដោយនិយាយពីគុណសម្បត្តិនឹងបទពិសោធន៍ដ៏ធំសម្បើមរបស់លោក បាយដិន តែក៏ហាក់ដូចជាមិនអាចទាក់ទាញទឹកចិត្តលោក បាយដិន ឲ្យបោះបង់បេក្ខភាពលោក បាននៅឡើយទេ ហើយការស្ទង់មតិក្រោយគេបង្អស់ ក៏នៅតែចង្អុលថា«លោក បាយដិន នៅតែមានប្រជាប្រិយភាពអាចយកឈ្នះលោកឌណាល ត្រាំ បាននៅឡើយ»។ ចុះបើលោក ជោ បាយដិន ដកខ្លួនថយ នៅ៤ខែមុនពេលបោះឆ្នោតទៅវិញមែននោះ តើមិនមែនជាការទុកឱកាសឲ្យលោកត្រាំយកឈ្នះឆ្នោតបានដែរទេដឹង?

គ្រប់អ្នកសង្កេតការ បាននិយាយពិលោកត្រាំវិញម្តងថា«លោកត្រាំមិនដែលនិយាយអ្វីគួរឲ្យជឿបាននោះទេ» រីឯន


President Joe Biden


Former President Donald Trump

យោបាយរបស់លោកវិញក៏គេបានឃើញម្តងរួចទៅហើយ គឺការបង្ខំហាក់ទៅទប់ស្កាត់អន្តោប្រវេសន៍ ដោយស្ងប់ខ្ទើមនៅពេលដែលសហរដ្ឋត្រូវការកម្លាំងពលកម្ម, ដកខ្លួនចេញពី«អ្នកកាពារពិភពលោក»នៅពេលដែលក្រុមប្រទេសផ្តាច់ការ«មូស្លីម»ចិននឹងរុស្ស៊ី គម្រាមកំហែងសម្ព័ន្ធមិត្រលោកសេរី...។ល។ លោកត្រាំមានគម្រោងពង្រឹងនយោបាយដដែលនេះឲ្យរឹតតែខ្លាំងថែមទៀត ដើម្បីរក្សារបបផ្តាច់ការមួយឡើងវិញ នៅជាមួយក្រុមប្រឹក្សាខ្លួនមួយ, នៅពេលអ្នកកាសែតចាប់ដំណឹងនោះបាន តែត្រាំបានប្រកែកថា«ខ្ញុំឥតមានពាក់ពន្ធក្នុងរឿងនោះទេ» គួរឲ្យចង់សើច ពីព្រោះអ្នកសរសេរគម្រោងឃោសនាទាំងនោះសុទ្ធសឹងជាបុគ្គលិកសេដ្ឋវិមាននៃអតីតរដ្ឋបាលត្រាំ កាលលោកនៅកាន់អំណាចនោះទាំងអស់។ លោក ឌណាល ត្រាំ មានអំនួតថាសេដ្ឋកិច្ចកាលជំនាន់លោកមិនមានឱនភាពដូចជំនាន់លោក បាយដិន នោះទេ តែតាមពិតទៅ ការដកខ្លួនចេញពីពិភពលោក គឺជា«លុយដែលសល់មិនបានចាយ»វាយសម្រាប់កាពារសេរីភាព ពុំមែនលុយរកស៊ីបានពីប្រាក់ចំណេញនោះទេ។ រីឯការប្រយុទ្ធទប់ទល់នឹងកូវិដ១៩របស់រដ្ឋបាលលោកត្រាំ វិញ សហរដ្ឋអាមេរិកគឺជាប្រទេសដែលមានមនុស្សរងគ្រោះស្លាប់ច្រើនជាងគេបង្អស់ក្នុងពិភពលោក(ស្លាប់ជាច្រើនង៦០ ០០០នាក់) ពីព្រោះលោកប្រធានាធិបតី ត្រាំ ពុំបានជឿជាក់ដល់ការណែនាំ របស់ក្រុមប្រឹក្សាគ្រូពេទ្យទេនៃរដ្ឋបាលខ្លួននោះទេ។ ចំណែកខាងគណបក្សសាធារណរដ្ឋវិញ ពុំឃើញមាននរណាទាមទារឲ្យលោក ត្រាំ ដកបេក្ខភាពចេញ នៅពេលដែលលោកកំពុងមានទោសជាប់ស្អែកស្អះពេញខ្លួនផងទេ, នោះហើយដែលគេសង្ស័យថាគណបក្សសាធារណរដ្ឋ អាចនឹងខូចកេរឈ្មោះ ពុំអាចមានលទ្ធភាពនឹងឡើងដណ្តើមដំណែងប្រធានាធិបតីនៃសហរដ្ឋអាមេរិក ជាយូរអង្វែងបាន។ ទោះជាយ៉ាងនេះក្តី ក៏ ត្រាំនៅតែមានប្រជាប្រិយភាពខ្ពស់ដដែល(បាន៥០%)នាចំណោមអ្នកបោះឆ្នោតអាមេរិកាំង។

ក្នុងរូបភាពលោក ជោ បាយដិន បន្ទាប់ពីការជជែកដេញដោលមក លោក បាយដិន ទទួលបានប្រជាប្រិយភាពតែ៤៨%តែប៉ុណ្ណោះ ដូច្នេះតើបេក្ខជនប្រធានាធិបតីគណពក្សប្រជាធិបតេយ្យនៅតែជាលោក បាយដិន ដដែលឬក៏យ៉ាងណានោះ បហាសន្និបាទបក្ស នៅខែក្រោយ នឹងវះកាត់ប្រសិនបើករណីជោ បាដិន មិនបានប្រសើរឡើងទេនោះ។ សម្រាប់គណបក្សប្រជាធិបតេយ្យគេពុំមានចែងថា ឲ្យមានបេក្ខជនប្រឆាំងនឹងបេក្ខជនប្រធានាធបតីចេញ សម្រាប់អាណត្តិទី២នោះទេ ប៉ុន្តែលោក បាយដិន អាចនឹងសម្រេចចិត្តដោយខ្លួនឯងប្រសិនមានការធានាថានឹងមានបេក្ខជន ឬ បេក្ខនារីណាមួយ អាចនឹងយកឈ្នះ ឌណាល ត្រាំ បាន? បើមិនដូច្នោះទេ លោកនឹងបន្តភារៈកិច្ចជាបប្រធានាធិបតីជាមួយនឹងលោកស្រី គាមាឡា ហារីស ហើយបើសុខភាព ពាយដិន នៅតែមិនប្រសើរទេនោះ គឺលោកស្រី ហារីស នឹងក្លាយជា«ប្រធានាធិបតីជាស្ត្រីស្បែកខ្មៅបំបូង» សម្រាប់សហរដ្ឋអាមេរិកនោះហើយ។

នៅមុនពេលបោះឆ្នោតនេះនៅមានបេក្ខភាពជាជម្រើសគណបក្សប្រជាធិបតេយ្យច្រើនដែរ សម្រាប់ជំនួសលោក បាយដិន ក្នុងលំដាប់ទី១ គឺលោកស្រី មីសែលអូបាម៉ា ភរិយាអតីតប្រធានាធិបតី បារ៉ាក់ អូបាម៉ា ដែលការស្ទង់មតិថា«អាចយកឈ្នះលោក ត្រាំ បាន»តែលោកស្រីនិយាយថា«មិនស្វែងរកដំណែងនោះទេ»,រីឯអ្នកឯទៀត មិនច្បាស់ជាយកឈ្នះលោក ត្រាំ បានទេ។ គេអាចនឹងមានព្រឹត្តការភ្ញាក់ផ្អើលមួយបានដែរ នៅពេលសមាជគណបក្ស សម្រាប់តែងតាំងបេក្ខជនប្រធានាធិបតី ខាងគណបក្សប្រជាធិបតេយ្យ នាខែសីហាខាងមុខថា«នរណាជាអ្នកឈរឈ្មោះប្រជែងលោក ត្រាំ បាន?»។

ទៅមើលគណបក្សសាធារណរដ្ឋវិញ គេគ្មានព្រាងទុកទេថា បើគ្មានលោក ត្រាំ ទៅ(អាយុ៧៨ ហើយ)ពុំមាននរណាត្រៀមសម្រាប់ជំនួសនៅឡើយទេ មិនតែប៉ុណ្ណោះ តុលាការកំពូល(ភាគច្រើនតែងតាំងដោយគណបក្សសាធារណរដ្ឋ) ទើបនឹងប្រកាសបញ្ជាក់ពីអត្ថន័យនៃច្បាប់ ដែលថា«លោក ត្រាំ មិនអាចមានទោសទេ នៅពេលអនុវត្តន៍កិច្ចការក្នុងដំណែង លើកលែងតែករណីជាឯកជន» ដូច្នេះការដែលបានញុះញុងឲ្យមានកូដកម្មនៅវិមានកាពីតូល បណ្តាលឲ្យស្លាប់កងកាពារច្រើននាក់ មិនពាក់ព័ន្ធនឹងលោក ត្រាំ ទេ៕

# មហាសន្និបាទកំពូលទី៧៥ របស់អង្គការ«អូតង់»នៅវ៉ាស៊ីនតុន

អឺរ៉ុប ថ្ងៃទី១០កក្កដា២០២៤

មហាសន្និបាទកំពូលទី៧៥ របស់អង្គការ«អូតង់»ឬក៏ហៅម្យ៉ាងទៀតថា«ណេតូ»សម្រាប់ឆ្នាំ២០២៤ បានប្រព្រឹត្តទៅនៅរដ្ឋធានីវ៉ាស៊ីនតោន នៃ



ប្រធានាធិបតីអ៊ុយក្រែន វ្លូឌីមៀ ជេឡិនស្គី នឹងអគ្គលេខាធិការណេតូ លោក ជិន ស្តូលតិនប៊ែក នៅវេទិកាណេតូវ៉ាស៊ិនតោន

សហរដ្ឋអាមេរិក ដោយមានប្រទេសអឺរ៉ុប៣២ប្រទេសចូលរួម ជាមួយនឹងសហរដ្ឋអាមេរិក អូស្ត្រាលី កាណាដា ជប៉ុន នឹង កូរ៉េខាងត្បូង ហើយក៏មានវត្តមាននៃប្រធានាធិតីវ្លូឌីមៀ ជេឡិនស្គីនៃប្រទេសអ៊ុយក្រែនថ្វីត្បិតតែពុំទាន់បានចូលជាសមាជិក«ណេតូ»នៅឡើយ ផងដែរ។ «ណេតូ»គឺជាអង្គការសង្គ្រាមដ៏ធំមួយ ក្នុងពិភពលោក សម្រាប់ការពារសហភាពអឺរ៉ុប នឹងប្រទេសជាដៃគូរទាំងអស់ ដែលបានចូលជាសមាជិក ហើយអង្គការនេះមានអាយុ៧៥ឆ្នាំហើយ។

លោកប្រធានាធិបតីអាមេរិកាំង ជាអ្នកបើកអង្គប្រជុំទទួលភ្ញៀវ«ណេតូ»ថ្ងៃទី១០កក្កដានេះ ជាឱកាសបង្ហាញកិត្យានុភាពនៃសហរដ្ឋអាមេរិក នៅចំពោះមុខពិភពលោកផង នឹងឥទ្ធិពលរបស់ខ្លួនលោកផ្ទាល់ផងនៅ៤ខែមុនការបោះឆ្នោតរបស់លោក ចំពោះមុខពលរដ្ឋអាមេរិកាំងម្ចាស់ឆ្នោតថា«លោកនៅតែមានស្មារតីនឹងសុខភាពមាំមួន សម្រាប់ដឹកនាំពិភពលោកបាននៅឡើយ»។ លោកបាយដិន បានរំលឹកក្នុងសុន្ទរកថារបស់លោក«ណេតូបានធ្លាក់ទៅដល់បាតដីនាជំនាន់ ឌណាល ត្រាំ បើកុំតែលោកបានមកស្រោចស្រង់ទាន់ពេល...ហើយពេលនេះមាំមួនវិញហើយ»។ នៅលើប្រយោគនេះមហាសន្និបាទ«ណេតូ»ក៏បានត្រៀមរៀបចំខ្លួន បង្កើនធន់ធាន នឹងរៀបគម្រោងសម្រាប់ទប់ទល់ក្រែងស្ថានការ ឌណាល ត្រាំ អាចត្រឡប់មកកាន់អំណាចនៅសហរដ្ឋអាមេរិក ជាថ្មីម្តងទៀត។

ក្រៅពីពង្រឹងជំហរដោយជំឡើងកម្លាំងសេដ្ឋកិច្ចអង្គការ មានទាំងបង្កើនទំនើបកម្មយុទ្ធសាស្ត្រ អាវុធទំនើប



ប្រធានាធិបតីអ៊ុយក្រែន វ្លូឡូឌីមៀ ជេឡិនស្គី និងប្រធានាធិបតីសហរដ្ឋអាមេរិក ចូបៃ ឌិន

រាប់ទាំងប្រព័ន្ធការពារ«នុយក្លេអ៊ែរ»ទៀតផង នោះ «ណេតូ»បានស្វាគមន៍សមាជិកថ្មីដែលនៅជាប់នឹងព្រំដែនប្រទេសរុស្ស៊ី គឺប្រទេសស៊ុយអែដ នឹង ហ្វាំងឡង់, «ណេតូ»បានថ្កោលទោសប្រទេសរុស្ស៊ីយ៉ាងចំពោះមុខថា«ជាប្រទេសដែលបានធ្វើសង្គ្រាមឈ្លានពានលើប្រទេសអ៊ុយក្រែន ដែលជាប្រទេសមានអធិបតីយ្យភាព មានប្រជាធិបតេយ្យ ហើយនឹងមានថ្នាក់ដឹកនាំព្រមទាំងប្រជាពលរដ្ឋអង់អាចដែលបានក្រោកតស៊ូប្រឆាំងនឹងរុស្ស៊ីវិញ ដើម្បីការពារទឹកដីរបស់ពួកគេ...»។ «ណេតូ»បានចំណាយពេលយ៉ាងច្រើនសម្រាប់ពិភាក្សាពីករណីនៃប្រទេសអ៊ុយក្រែន ដែលកំពុងតែត្រៀមខ្លួនចូលជាសមាជិករបស់«ណេតូ» ដោយអ៊ុយក្រែនត្រូវតែគោរពលក្ខខណ្ឌមួយចំនួន របស់ណេតូដែលអ៊ុយក្រែនមើលឃើញថា«ជាមួយណេតូ ប្រជាពលរដ្ឋអ៊ុយក្រែននឹងពេញចិត្តដោយរស់នៅមានសេរីភាព នឹងមានការគោរពលទ្ធិប្រជាធិបតេយ្យ នឹងរួមគ្នាជួយការពារទឹកដីជូនតាខ្លួនបានផង» ។

នៅក្នុងមហាសន្និបាទនោះ ណេតូបានសន្យាជួយអ៊ុយក្រែនក្នុងផ្នែកផ្តល់សម្ភារៈយោធា អ្នកបង្ហាត់បង្វឹក សម្រាប់ទប់ទល់នឹងសង្គ្រាមឈ្លានពានរបស់រុស្ស៊ី រហូតដល់បានជោគជ័យជាស្ថាពររំដោះដែនដីអ៊ុយក្រែនមកវិញ រាប់ទាំង«គ្រីមេ»ផងដែរ, ហើយនឹងជួយរៀបប្រទេសឲ្យបានស្របទៅតាមលក្ខន្តិកៈរបស់ណេតូ នឹងស្របគន្លងច្បាប់ នៃសន្តិភាពពិភពលោក តាមការណែនាំរបស់អង្គការសហប្រជាជាតិផង ។ ណេតូមានការកោតសសើរយ៉ាងខ្លាំង ដល់ប្រជាពលរដ្ឋអ៊ុយក្រែន នឹងការដឹកនាំរបស់ប្រធានាធិបតី ជេឡិនស្គី ចំពោះការតស៊ូយ៉ាងស្វិតស្វាញ មិនព្រមឲ្យលោកប្រធានាធិបតី ពូទីន យកប្រទេសអ៊ុយក្រែនធ្វើជារណបបានឡើយ ហើយណេតូក៏បានសន្យាដូចសហរដ្ឋអាមេរិកដែរថា«នឹងជួយអ៊ុយក្រែនឲ្យឈ្នះរុស្ស៊ី ឲ្យទាល់តែបាន»។

ជាមួយគ្នានោះដែរ «ណេតូ»ក៏បានថ្កោលទោសប្រទេសផ្តាច់ការនិយម៣ទៀត ដែលមានកូរ៉េខាងជើង នឹងប្រទេសអ៊ីរ៉ង់ ដែលបានជួយផ្គត់ផ្គង់គ្រាប់កាំភ្លើង គ្រាប់«មីស៊ីល» នឹងយន្តហោះ«ដ្រូន» ឲ្យទៅរុស្ស៊ី យ៉ាងខុសច្បាប់ សម្រាប់យកទៅឈ្លានពានប្រទេសអធិបតេយ្យមួយទៀត ហើយនឹងថ្កោលទោសដល់ប្រទេសចិនប៉េកាំង ដែលទើបនឹងចុះហត្ថលេខាធ្វើសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយ ជាមួយប្រទេសរុស្ស៊ី ក្នុងគោលបំណងដូចគ្នា។ ចំណែកឯ«ណេតូ»វិញ នឹងក្រុមប្រទេសលោកសេរីវិញ ក៏បានជួយសព្វាវុធដល់អ៊ុយក្រែនដូចគ្នា ក៏ប៉ុន្តែធ្វើទៅតាមរយៈអង្គការក្រៅរដ្ឋាភិបាល ដែលធ្វើការស្របច្បាប់អន្តរជាតិ ស្របកិច្ចព្រមព្រាង ដោយមិនលូកដៃដោយចំពោះ ទៅក្នុងសង្គ្រាមរុស្ស៊ី នឹង អ៊ុយក្រែននោះទេ តែតោះជាយ៉ាងនោះក្តី រុស្ស៊ីនៅតែចោទប្រកាន់«ណេតូ»ថាបានលូកដៃ ទៅជួយអ៊ុយក្រែនដោយផ្ទាល់ ដែលជាលេសសម្រាប់រុស្ស៊ីពង្រីកសង្គ្រាមឲ្យកាន់តែធំ ហើយប្រើអាវុធ«នុយក្លេអ៊ែរ»។

នៅចុងបញ្ចប់នៃមហាសន្និបាទ «ណេតូ»ប្រធានាធិបតីអ៊ុយក្រែន ជេឡិនស្គី បានសម្តែងការអបអរសាទរ ចំពោះការគាំទ្ររបស់ណេតូ ដោយផ្តល់ជំនួយជាបន្ទាន់ចំនួ៤០ពាន់លានដុល្លា នឹងប្តេមបញ្ជូនយន្តហោះប្រដេញ១០០គ្រឿងទៅកាន់អ៊ុយក្រែន ដោយប្តើមពីការបញ្ជូនយន្តហោះពីដាណឺម៉ាក នឹង ប៉េអ៊ីបាទៅឲ្យ... ប៉ុន្តែលោក ជេឡិនស្គី នៅមានការព្រួយបារម្ភមួយទៀតថា«តើទៅអនាគតសហរដ្ឋអាមេរិក នៅតែជួយអ៊ុយក្រែនបានឬក៏យ៉ាងណា? សហភាពអឺរ៉ុបតែម្នាក់ឯងពុំអាចទ្រោលសង្គ្រាមនៅអ៊ុយក្រែនប្រឆាំងរុស្ស៊ី រួចទេ!» ទាំងអស់គ្នាបានយល់ពីប្រយោគនេះ គឺភាពមិនច្បាស់លាស់ ស្តីពីការបោះឆ្នោតនៅសហរដ្ឋអាមេរិក ខែវិច្ឆិកាខាងមុខ៕



តមកពីទំព័រទី ០២

## កម្ពុជាចាប់យកសកម្មជនមាតា...

ដឹកនាំដោយអង្គការបរិស្ថានមានឈ្មោះថា មាតាធម្មជាតិ កម្ពុជា (Mother Nature Cambodia) ពីបទ "ក្បត់ជាតិ" និង "ប្រមាថព្រះមហាក្សត្រ"។ ពួកគេត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគារពី ៦ ទៅ ៨ ឆ្នាំ។ លោក Montse Ferrer នាយករងផ្នែកស្រាវជ្រាវប្រចាំតំបន់របស់អង្គការលើកលែងទោសអន្តរជាតិ ហៅថា (Amnesty International) មានប្រសាសន៍ថា "ការសម្រេចចិត្តថ្ងៃនេះ គឺជាការវាយប្រហារដ៏ឃោឃៅមួយទៀតសម្រាប់សង្គមស៊ីវិលកម្ពុជា។ អង្គការមាតាធម្មជាតិកម្ពុជា គឺជាក្រុមសកម្មជនដ៏ល្បីមួយដែលយកចិត្តទុកដាក់ទប់ស្កាត់ភាពរិចរឹលហិនហោចបរិស្ថាន ដែលបង្កឡើងដោយអំពើពុករលួយដ៏រ៉ាំរ៉ៃនៅក្នុងប្រទេស។ ជំនួសឱ្យការស្តាប់មេដឹកនាំវ័យក្មេងនៅជួរមុខនៃចលនាបរិស្ថានរដ្ឋាភិបាលកម្ពុជាបានជ្រើសរើសដាក់គុកអ្នកដែលហ៊ាននិយាយ"។

អង្គការមាតាធម្មជាតិកម្ពុជា គឺជាក្រុមយុវជនដ៏ល្បីមួយ ដែលដឹកនាំដោយជនជាតិអេស្ប៉ាញ ឈ្មោះ អាឡិចហ្សង់ដ្រូ ហ្គាន់ហ្សាឡេស ដាវីដសុន (Alegandro Gonzalez-Davidson) ដែលត្រូវបានកាត់ទោសកំបាំងមុខចាប់តាំងពីគាត់ត្រូវបានហាមឃាត់មិនឱ្យចូលប្រទេស។ អាឡិចហ្សង់ដ្រូ លោក ស៊ុន រ័ត្ន និងលោក យឹម លាងហ៊ី ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល ៨ ឆ្នាំ ពិន័យជាប្រាក់ ១០.០០០.០០០ រៀល ស្មើនឹង ២៥០០ ដុល្លារអាមេរិក ពីបទ "ក្បត់ជាតិ" និង "ប្រមាថព្រះមហាក្សត្រ"។

ជនជាប់ចោទ ៧ នាក់ផ្សេងទៀត ពីបទ "ក្បត់ជាតិ" ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ ៦ ឆ្នាំ រួមមាន លោក លី ច័ន្ទតារាវុធ លោកធន់ រដ្ឋា កញ្ញាឡុង គន្ធា កញ្ញាភួន កែវរស្មី លោកប៊ិញ ពិសិដ្ឋលោករ៉ៃ រស្មី និងភោគ យឿយ។ ការចោទប្រកាន់គឺផ្អែកលើសកម្មភាពបរិស្ថានដោយសន្តិវិធីរបស់ក្រុមយុវជនពីឆ្នាំ ២០១២ ដល់ឆ្នាំ ២០២១។

ទណ្ឌិតចំនួន ៤ នាក់៖ លោកចាន់តារាវុធ លោករដ្ឋា កញ្ញាកែវ រស្មី និងកញ្ញា គន្ធា បានចូលរួមសវនាការ ហើយត្រូវបានអាជ្ញាធរដែលស្លៀកពាក់ឯកសណ្ឋាន និងស៊ីវិលចាប់ខ្លួនដោយហិង្សាភ្លាមៗបន្ទាប់ពីសាលក្រម។ ពួកគេបានចូលរួមជាមួយអ្នកគាំទ្រនៅខាងក្រៅបន្ទប់សវនាការ ហើយស្លៀកសម្លៀកបំពាក់ពណ៌ស និងក្រណាត់ពាក់ក្បាលពណ៌ស ដែលមានអក្សរនិយាយថា "យុត្តិធម៌"។ សម្លៀកបំពាក់សតំណាងឱ្យការកាន់ទុក្ខចំពោះការស្លាប់របស់ប្រព័ន្ធយុត្តិធម៌ ។ វាត្រូវបានគេរាយការណ៍ថា ប៉ូលីសយ៉ាងហោចណាស់ ៥០ នាក់បានវាយលុកពួកគេយ៉ាងលឿន ដោយអូស និងរុញពួកគេចូលទៅក្នុងរថយន្តដែលកំពុងរង់ចាំ



After the court verdict, Chandaravuth, Ratha, Keoraksmey, and Kunthea joined by supporters outside of the courthouse in Phnom Penh.

ដោយហិង្សា។ យ៉ាងហោចណាស់ពីរនាក់ក្នុងចំណោមពួកគេត្រូវបានគេអូសទាញកចូលរថយន្ត។

អង្គការការពារសិទ្ធិមនុស្ស ហៅកាត់ថា លីកាដូ បានចេញសេចក្តីថ្លែងការណ៍ថ្កោលទោសការកាត់ទោស និងការចាប់ខ្លួនកាលពីថ្ងៃទី២ ខែកក្កដា ដោយបញ្ជាក់ថា វាជារឿងអាម៉ាស់សម្រាប់ជាតិយើង។ ការបំបិទមាត់អ្នកការពារបរិស្ថាន និងការកំណត់លក្ខណៈនៃការតស៊ូមតិដោយសន្តិវិធីរបស់យុវជន ទៅជាការគំរាមកំហែងដល់រដ្ឋ គឺជាការចំអកដល់យុត្តិធម៌"។

គេមិនដឹងថាតើលោក លាង ហ៊ី ត្រូវបានចាប់ខ្លួនដោយរបៀបណា។

តទៅទំព័រទី២២

## Cambodia Jailed Ten Mother Nature Activists for “Plotting Against the State”

From Page 14

By Soben Ung

July 2nd – Phnom Penh Court convicted ten environmental activists from an award-winning, youth led environmental group Mother Nature Cambodia for “plotting” and “insulting the King”. They were sentenced six to eight years in prison. Amnesty International’s Deputy Regional Director for Research, Montse Ferrer said, “Today’s decision is another crushing blow to Cambodia’s civil society. Mother Nature Cambodia is a renowned activist group that has brought attention to environmental degradation fueled by long-standing corruption in the country. Instead of listening to young leaders at the forefront of the environmental movement, the Cambodian government has chosen to jail those that dare to speak out.”

Mother Nature Cambodia is a well-known youth-led group, found by Spanish national Alegandro Gonzalez-Davidson, who also was tried in absentia since he was banned from entering the country. Alegandro, Sun Rath, and Yim Leanghy were sentenced eight years in prison with 10,000,000 riels fine which equal to $2,500 for “plotting against the state” and “insulting the King”

Seven others convicted for “plotting against the state” were sentenced to six years in prison including Ly Chandaravuth, Thun Ratha, Long Kunthea, Phuon Keoraksmey, Binh Piseth, Rai Raksa and Pork Khoeuy. The charges were based on the group’s peaceful environmental activism from 2012 to 2021.

Four of those convicted: Chandaravuth, Ratha, Keoraksmey, and Kunthea attended the hearing and were violently arrested by the authorities dressed in both uniform and civil clothes immediately after the verdict. They were joined with supporters outside the courtroom and wearing white clothes and white headbands that said “Justice”. White clothes signify mourning for the death ‘of the justice system’. It was reported that a group of at least 50 police rapidly swarmed them, violently dragging and shoving them into waiting cars. At least two of them were dragged by their necks.

The Cambodian Center for Human Rights (LICADO) released a statement condemning the conviction and the arrest on July 2nd stating it was “a shame for our nation. Silencing environmental defenders and characterizing their peaceful advocacy as a threat to the state is a mockery of justice.”

It is unclear how Leanghy was arrested. He did not attend the hearing that day. He also was transferred to prison.

All five activists are scattered to five different prisons across the country. Leanghy, Kampong Speu; Thun Ratha, Correctional Center 3 in Tbong Khmum; Daravuth, Kandal; Keoraksmey, Pursat provincial prison and Kunthea, Preah Vihear.

“This unprecedented move, so transparently aimed at breaking the spirits of the activists, also places a heavy burden on their families who will have to travel hundreds of kilometers to visit their loved ones or provide essential materials in under-resourced prisons…the detention of all five activists across the country is a violation of international standards on the humane treatment of prisoners,” wrote LICADO.

The trial of the ten Mother Nature activists began from May 29 to June 2024. On June 5, five Mother Nature activists staged protest outside of the courthouse, dressed in white and some held flowers. They refused to enter the courtroom because the authorities did not allow some media and supporters to attend the public hearing. The hearing proceeded anyway without any of the charged activists present.

Several members of the Mother Nature group were charged in 2021 after they documented a waste discharged into the Tonle Sap River, near the Royal Palace. Sun Ratha, Leanghy and Chandaravuth were arbitrary detained for five months under the same charges, according to an Amnesty report. Thun Ratha, Kunthea and Keoraksmey also were arrested in September 2020

Please see /21

Lowell
Primary Care Center
មណ្ឌលថែទាំសុខភាព Lowell

1075 Westford Street, Unit 204
Lowell, MA 01851 • (978) 455-7992

Lynn
Primary Care Center
មណ្ឌលថែទាំសុខភាព Lynn

280 Union Street, Unit 402
Lynn, MA 01901 • (781) 780-7755



Chhan Touch, FNP-BC
ឆាន់ ទូច



Practice Manager
Channa Khan, CMA
អ្នកគ្រប់គ្រងគ្រូពេទ្យ
ចាន់ណា ខាន់



Sophor Chhour, LMHC
សុភ័រ ឈួ



Nalyne Dom, FNP-BC
ណាលីន ដំ



Nida Lam, FNP-BC
នីដា ឡាម



Maredy Sar, DNP, NP-C
ម៉ារីឌី ស



Miadette Pheng-Phal, DNP, NP-C
មីយ៉ាដេត ផេងផល

Now Accepting New Patients
ឥឡូវនេះ បើកទទួលអ្នកជំងឺថ្មី

*Family Medicine*
*ថែទាំសមាជិកគ្រួសារ*

*Behavioral Health*
*ថែទាំសុខភាពផ្លូវចិត្ត*

We Accept MassHealth, Medicare and Other Health Insurances
Our Staff Speaks Khmer

យើងទទួល MassHealth Medicare និងការធានារ៉ាប់រងសុខភាពផ្សេងៗ
បុគ្គលិករបស់យើងនិយាយភាសាខ្មែរ




# អន្តោប្រវេសន៍រស់នៅក្នុងកណ្ដាប់ដៃនៃអ្នកនយោបាយ

អឺរ៉ុប ថ្ងៃទី១២កក្កដា២០២៤

ក្រុមអ្នកនយោបាយបារាំងគ្រប់និន្នាការ បានសង្រ្គិតមាត់ប្រឹងទាញយកចំណោញ កាលពីថ្ងៃទី៣០មិថុនា នៅពេលដែលលោកប្រធានាធិបតីម៉ាក្រុង បានប្រកាស ដោយមិនឲ្យនរណាដឹងខ្លួនជាមុនថា«លោករំលាយសភាចោល»ចំពេលដែលគណបក្សរបស់លោក កំពុងខូចខាចប្រជាប្រិយភាពស្របគ្នានឹងគណបក្សប្រឆាំងដ៏គួរឲ្យខ្លាចមួយ កំពុងកើនប្រជាប្រិយខ្ពស់ នៅពេលទើបនឹងបោះឆ្នោតសហភាពអឺរ៉ុប២០២៤ រួចមក។

ខ្ញុំជាជនអន្តោប្រវេសន៍មកពីកម្ពុជា បានទទួលសញ្ជាតិបារាំងហើយគិតថា«ខ្លួនអាចរួចពីការធ្វើបាបប្រកាន់ពូជសាសន៍ពីសាសន៍ដទៃហើយ តែសម្លេងឆ្នោតច្រើនណាស់ បានធ្វើឲ្យក្រុមរណសិរ្សជាតិ Front National ក្លាយជាតារាឯកនៃនយោបាយបារាំងជាលើកដំបូង»។ នៅពេលដែលខ្ញុំពិចារណាថា តើក្រុមរណសិរ្សជាតិFN ជាក្រុមអ្វី? មកពីណា? បំរុងធ្វើអ្វី? ពេលនោះទើបខ្ញុំព្រឺសម្បុរខ្លាក ដឹងថាគ្រោះកាចអាចមកដល់ម្ដងទៀតហើយ ក្នុងជីវិតភ្លេចខ្លួន នៃគ្រួសារអន្តោប្រវេសន៍ខ្មែរ នៅប្រទេសបារាំងមួយនេះ។

ក្រុមអ្នកនយោបាយរណសិរ្សជាតិ FN នេះ គេហៅថា ក្រុមស្ដាំផុតនិយម ដឹកនាំដោយ ឡឺប៉ិន (ឪពុក) ធ្លាប់មានប្រវត្តិជាក្រុមស្អប់ខ្ពើមជនជាតិដទៃ ដែលមករស់នៅលើដែនដីនៃប្រទេសបារាំង ក្រុមនេះតែងមានប្រជាប្រិយភាពនយោបាយធម្មតាប្រមាណជា១០%តែប៉ុណ្ណោះ កាលពីអម្លុងឆ្នាំ៨០ ហើយចំនួននេះពុំបានកើនឡើងច្រើនទេ នៅ៣០ឆ្នាំក្រោយមក។ នៅជំនាន់ឡឺប៉ិន(កូនស្រី) ក៏ក្នុងចំនួនមិនខុសគ្នាទេ ពុំបានធ្វើឲ្យជនអន្តោប្រវេសន៍ដូចជាខ្ញុំនេះ ព្រួយបារម្ភអ្វីដែរ ពីព្រោះក្រុមនោះ ពុំអាចក្លាយជាអ្នកដឹកនាំនយោបាយប្រទេស បានទេ។ ស្រាប់តែ ឆ្នាំ២០២៤នេះ ក្រុម FN នេះ បានកើនប្រជាប្រិយភាពស្ទុះដល់៣៤% ជាលំដាប់លេខ១ នៃអ្នកនយោបាយបារាំង ចូលទៅសភាអឺរ៉ុប តើហេតុអ្វី? គឺដោយសារការប្ដូរប្រធានថ្មី ជ័រដាន់ បាដែលឡាវ័យក្មេងអាចទាក់ទាញសមាជិកថ្មីបាន ហើយទី២ គាប់ជួនរដ្ឋាភិបាល លោក ម៉ាក្រុង បានភ្លាត់ស្នៀត រកមតិភាគច្រើនមិនបានដើម្បីអនុម័តច្បាប់ ក៏ប្រើមាត្រា៤៩.៣ច្រើនដង ច្រើនសារ មានទាំងធ្វើច្បាប់ចូលនិវត្តន៍ដែលតម្លើងអាយុចូលនិវត្តន៍ពី៦២ទៅ៦៤ឆ្នាំ ដែលរឹតតែដុតកំហឹងម្ចាស់ឆ្នោត ឲ្យងាកទៅរកគណបក្សណាដែលជាទណ្ឌកម្មធ្លាក់លើ ម៉ាក្រុង ។




លទ្ធផលបោះឆ្នោតជុំទី១នៅសភាបានទៅ FN ជាក្រុមលេខ១, ក្រុមលេខ២ បានទៅក្រុមឆ្វេងនិយម មានក្រុមកុម្មុយនិស្ត សង្គមនិយម នឹងមានឆ្វេងផុតនិយម ដែលធ្លាប់មានប្រវត្តិឃោរឃៅនឹងជូរចត់នៅកម្ពុជា នៅជាមួយផង, រីឯក្រុមឆ្វេងឬស្ដាំកណ្ដាលនិយម ធ្លាក់ទៅលេខ៣ នោះហើយដែលជាសោកនាថកម្មថ្មីរបស់ជនអន្តោប្រវេសន៍ ដែលថា«ចុះទឹកក្រពើ ឡើងលើខ្លា» តើយើងទៅខាងណា ទើបបានសុខ? ពេលឮគេហ៊ោកញ្ជ្រៀវ ពីជ័យជំនះរបស់គេ ពីការបញ្ជូន ជ័រដាន់ ទៅវិមានម៉ាទីញ៉ុង, ឬនៅ៣ឆ្នាំក្រោយ គេបញ្ជូនគ្នាទៅវិមានអេលីស្សេទៀត…ចប់ហើយជនអន្តោប្រវេសន៍បារាំងខ្ញុំ គ្មានវិធីទប់ទល់កុំឲ្យ ជ័រដាន់ ទៅធ្វើជានាយករដ្ឋមន្ត្រីបានទេ ! តែព្រឹត្តិការថ្មីមួយបានកើតឡើង គឺក្រុមនយោបាយឆ្វេង នឹងឆ្វេងផុតនិយមឯណោះ ក៏ខ្លាចមិនចង់ឃើញក្រុម FN ទៅកាន់ម៉ាទិញ៉ុង ដូចគ្នាដែរ ដូច្នេះក៏លេចមធ្យោបាយថ្មីសម្រាប់ទប់ស្កាត់

តទៅទំព័រទី១០

# Immigrants In The Hands of Politicians

Europe July 12, 2024

French politicians of all walks of life rallied on June 30, when President Macron promptly announced that he "dissolved the parliament" at a time when his party was collapsing.

Popularity in line with a formidable opposition party is gaining popularity in the run-up to the 2024 EU elections.

I am an immigrant from Cambodia, granted a French citizenship and thought, "I can escape racism from other races, but a lot of votes made Front National become the star of French politics once again." First, when I consider what the Front National is? Where are you from?

What are you planning to do? Only then I realize that the plague could come again in the forgotten life of this Cambodian immigrant family in France.

The Front National politicians, known as the far-right extremists led by Le Pen (father), had a history of hating other ethnic groups who came to live on French soil. Only during the 1980s, and that dimenion did not increase much 30 years later. In the Le Pen (daughter) generation, the dimension was not different, not to worry about immigrants like me, because the group could not become the country's political leader.

Suddenly, in 2024, the Front National group has increased its popularity to 34%, the number one French politician entering the European Parliament. Why? Because of the change of new president, the young Jordan Badela was able to attract new members. Both make a retirement law that raises the retirement age from 62 to 64, which further inflames the anger of voters to turn to any party, which is a punishment that falls on Macron.

The results of the first round of parliamentary elections went to National Front Party as the first group, the second group went to the left, the communist group, the socialist group, and the leftist group, which had a history of brutality and bitterness in Cambodia, and the left group. Or the center-right falls to the third, which is the new tragedy of the immigrants that going down the water face crocodile, going up the shore face the tiger", where do we go to be happy?

When they hear the triumph of their

Please see /10


ផ្សារកសិដ្ឋាន
THE FARM MARKET AT MILL NO. 5
ផលិតផលកសិដ្ឋាន • ផ្លែឈើ • ស៊ុត • ទឹកឃ្មុំ
មីអ៊ីតាលី • មីអ៊ីតាលី• នំប៉័ង • នំដូណាត់ • ស្រាបិតពីទឹកឃ្មុំ
យ៉ាអួរ • ទឹកឈរមេស • ប្រូម៉ា • ចំណីឆ្កែ • នំឃុកឃី • ជ្រក់
ជុំណាប់ និងឈៀមនឈឿនមិខឈរទៀត!



FARM PRODUCTS • FRUITS • EGGS • BREADS • HONEY
SPAGHETTI • DONUTS • WINE BREWED FROM HONEY
YOGURT • CHILI SAUCE • MAYONNAISE • DOG FOOD
COOKIES • PICKLES • CONFECTIONERY AND MORE!
NOW ACCEPT SNAP + HIP
ឈរៀងរាល់ថ្ងៃអាទិតយ
EVERY SUNDAY
10 AM - 1 PM
250 JACKSON ST. LOWELL, MA
@FARMLOWELL @MILLNO5 MILLNO5.COM

# ជំនន់ទឹកភ្លៀងនៅរាជធានីភ្នំពេញនៅតែជាបញ្ហាដដែលៗ

ដោយ: ហេង លី

ទឹកជំនន់លាយឡំនឹងទឹកលូកខ្វក់នៅក្នុងរាជធានីភ្នំពេញ នៅតែជាបញ្ហារ៉ាំរ៉ៃដែលបង្ករំខានដល់ការរស់នៅរបស់ប្រជាពលរដ្ឋនៅពេលភ្លៀងធ្លាក់ម្តងៗ បើទោះបីជារដ្ឋាភិបាលអះអាងថាបានរៀបចំប្រព័ន្ធលូរំដោះទឹក និងសន្យាបញ្ចៀសជំនន់ទឹកភ្លៀងច្រើនឆ្នាំទៀត នេះក្តីបញ្ហានេះនាំឲ្យប្រជាពលរដ្ឋរស់នៅក្រុងភ្នំពេញអស់ជំនឿលើការសន្យារបស់រដ្ឋាភិបាល និងប្រសិទ្ធភាពនៃការងាររបស់អាជ្ញាធរក្រសួងពាក់ព័ន្ធ ដែលគាត់ផ្លូវដាក់លូរាល់ឆ្នាំតែរាជធានីភ្នំពេញនៅតែរងការជន់លិច ដោយសារទឹកភ្លៀង បើទោះបីជាទីក្រុងភ្នំពេញមានទីតាំងនៅក្បែរទន្លេ ហើយរដ្ឋាភិបាលធ្លាប់ទទួលបានជំនួយបរទេស មកស្តារប្រព័ន្ធលូរាប់លានដុល្លារ ជាច្រើនឆ្នាំមកហើយក្តីតែជំនន់ទឹកភ្លៀងបន្តជន់លិចផ្លូវថ្នល់ និងផ្ទះសម្បែងប្រជាពលរដ្ឋមួយចំនួននៅតែបានកើតឡើង រាល់ពេលភ្លៀងធ្លាក់ម្តងៗ ពលរដ្ឋរស់នៅសង្កាត់ផ្សារថ្មីទីមួយ ខណ្ឌដូនពេញ កញ្ញា ស៊ុន រស្មី បានប្រាប់ទៅវិទ្យុវីអូឌីនៅថ្ងៃទី០៥ ខែកក្កដា នេះថាពេលភ្លៀងធ្លាក់ម្តងៗ តំបន់នេះ តែងតែប្រឈមភាពលិចលង់លាយឡំជាមួយនឹងទឹកលូកខ្វក់ហើយហូរចូលផ្ទះសម្បែងពលរដ្ឋបង្កការខូចខាតទ្រព្យសម្បត្តិនិងបង្កឲ្យមានជំងឺសើស្បែកផងដែរកញ្ញាបន្តថានៅពេលនេះធ្វើដំណើរលើដងផ្លូវ ក៏កាន់តែជួបការលំបាកទៅទៀត ដោយសារតែទឹកលិចមិនអាចមើលឃើញជង្ហុកដែលបានបង្កគ្រោះថ្នាក់ជាញឹកញយ " នៅពេលដែលទឹកលិចខ្លាំង យើងមើលស្ថានភាពផ្លូវអត់ឃើញ មើលអត់ដឹងថាកន្លែងណាមានជង្ហុក មានរណ្តៅ ឬមានកន្លែងណាដូចថាកន្លែងខ្លះដូចដីបាក់ស្រុតអីចឹងទៅវាសល់រណ្តៅ សល់អីអីចឹងទៅ កន្លែងខ្លះមើលអត់ឃើញទេហើយពេលយើងជិះទៅវាធ្វើអោយយើងគ្រោះថ្នាក់" នៅពេលទឹកលិច យើងមើលឃើញអ៊ីចឹងនៅពេលគេយកទៅធ្វើជាឧបករណ៍ជាការគ្រោះថ្នាក់ផងដែរនៅពេលធ្វើដំណើរ ចំណែកឯប្រជាពលរដ្ឋម្នាក់ទៀតរស់នៅសង្កាត់ទឹកថ្លាខណ្ឌសែនសុខ លោក ធី ថន បានឲ្យដឹងថាបើទោះបីជាមេឃឈប់ភ្លៀង ហើយក្តីទឹកនៅតែបន្តដក់នៅបរិវេណផ្ទះដែលលោករស់នៅដោយសារតែបច្ចេកទេស រៀបចំប្រព័ន្ធលូនៅខ្វះស្តង់ដារ និងការទុកដាក់សំរាមមិនបានត្រឹមត្រូវបណ្តាលឲ្យស្ទះលូដែលកំពុងតែរំដោះទឹកបានតិចតួចស្រាប់នោះ លោកបន្តថាជំនន់ទឹកភ្លៀង រ៉ាំរ៉ៃបែបនេះបានធ្វើឲ្យសម្ភារៈនៅក្នុងផ្ទះ ដូចជា តុ ទូ និង



ជំនន់ទឹកភ្លៀងធ្វើឲ្យផ្លូវនៅទីក្រុងភ្នំពេញលិចស្ទើរតែទាំងស្រុង

ម៉ូតូ រងការខូចខាតដោយសារតែត្រាំទឹកស្អុយយូរថ្ងៃប៉ះពាល់ទៅដល់ទ្រព្យសម្បត្តិមួយចំនួន ដូចជាម៉ូតូអី បើជិះពួកគេឌ្រីមហុងដា អីក៏នឹងចូលបំពង់ស៊ីម៉ាំងម៉ូតូយើង អ៊ីចឹងទៅធ្វើ ម៉ូតូ យើងខូចមិនអាចជិះបាន វគងម៉ាស៊ីន គាំងអីមិនអាចជិះបាន ហើយសម្ភារៈផ្សេងទៀតដូចជា តុ ទូ ដែលយើងទុកនៅផ្ទាល់ដីយើងទុកមិនបាននៅផ្ទះហ្នឹងវាទឹកហ្នឹងមកលិចអីហ្នឹងវាខូចខាតតាមហ្នឹងផងដែរ កាលពីថ្ងៃទី០៣ ខែកក្កដាភ្លៀងធ្លាក់មួយមេធំ ដែលបណ្តាលឲ្យតំបន់ ខ្លះមួយចំនួននៅក្នុងរាជធានីភ្នំពេញ រងការជន់លិច ដូចជានៅតំបន់ទួលគោក ទួលសង្កែ ឫស្សីកែវ ទឹកថ្លា ជាពិសេសនៅម្តុំផ្សារដើមគរ ដែលទឹកលិច ឡើងដល់កម្ពស់កន្លះម៉ែត្រស្ទើរលិចបាត់របាំងថ្មពុះចែកទ្រូងផ្លូវ ជំនន់ទឹកភ្លៀងនៅពេលនោះបានធ្វើឲ្យប្រជាពលរដ្ឋជា តើអ្នកខូចម៉ូតូបណ្តើរតាមដងផ្លូវព្រោងព្រាត រីឯអ្នកខ្លះទៀតយករបាំងផ្សេងៗ មក

តទៅទំព័រទី១៤

# Floods in Phnom Penh Remain a Problem

By Heng Ly

Floods and sewage water in Phnom Penh remain a chronic problem that disrupts people's livelihoods when it rains, despite the government's claim to have set up a drainage system and promised to avoid flooding for years. This problem makes the people living in Phnom Penh lose faith in the promises of the government and the effectiveness of the work of the relevant ministries, which dig the roads and install sewage every year.

But Phnom Penh gets flooded by rain water although Phnom Penh is located near the river and the government has received foreign aid for millions to restore the sewer system for years, but floods continue to flood roads and people's houses in Sangkat Phsar Thmei I, Khan Daun Penh every time by rains.

Ms. Sun Raksmey told VOD on July 5 that when it rains, the area is often inundated with sewage water and flood people's homes, causing property damage and skin diseases. She said that now traveling on the road is even more difficult because we cannot see the pit holes, it is dangerous.

"When the floodwaters are high, we cannot see the road, we do not see, we do not know where there are pits, many pits unfilled, so some places cannot be seen when we ride motorbike, it's dangerous."

When floods come, it is dangerous for traveling. A resident of Sangkat Teuk Thla, Khan Sen Sok, Mr. Thorn said that although the sky has stopped raining, water still flow in the area where he lives because lack of standard drainage system and improper storage of garbage, causing the sewer blockage. He said that rain has damaged household items such as tables, cabinets and motorcycles when it stays in water for a long time. It affects some properties such as motorcycles. If you ride Dream Honda motorbike, it cannot cross the flood. A flood damaged our motorcycle, the engine crashed. We cannot leave cabinets and tables on the floor because flooding can damage it.

On July 3, heavy rain caused flood to some areas in Phnom Penh like Toul Kork, Tuol Sangke, Russey Keo, Teuk Thla, and around Doeum Kor market, where the water level reached half a meter. Stone barriers splitting the road in flood caused damage to travelers' motorbikes. Residents used sandbags to prevent water from flowing into their houses even after two days of rain.

Phnom Penh Governor Khuong Sreng said briefly that he has been busy solving the problem, "I am in a hurry to solve the problem for the people. I thank you very much, nephew! According to the broadcast of the National Television on July 4, it said that the Phnom Penh Municipality, the Department of Public Works and Transport is preparing to install a large sewer system. Width of sewage is from one and a half meters to two and a half meters wide to relieve flooding in Phnom Penh. In addition, improve flood water pumping stations to avoid flooding on the roads in some areas where the water has not yet receded, such as in Russey Keo district.

Currently, the Phnom Penh Municipal Administration and the Japan International Cooperation Agency (JICA) are working together to study the feasibility of implementing flood prevention and control projects, the fifth phase improve the canal system covering the southwest of Phnom Penh.

Several lakes and canals in the areas were flooded, four Japanese projects at a total cost of more than 110

Please see /14



តមកពីទំព័រទី ០១

# តើវៀតណាមត្រៀមលក្ខណៈគ្រប់

ថ្ងៃទី ១២ ខែកក្កដា។ ) លោកប្រធាន ហ៊ុន សែន រដ្ឋសភាកម្ពុជា ឃួន សុដារី និងសមាគមវៀតណាមនៅកម្ពុជា។

លោកប្រធានាធិបតី បានចូលគាល់ព្រះមហាក្សត្រ នរោត្តម សីហមុនី ជួបពិភាក្សាការងារជាមួយលោក ហ៊ុន សែន ប្រធានគណបក្សកាន់អំណាចកម្ពុជា (CPP) លោកជំទាវឃួន សុដារី ប្រធានរដ្ឋសភាកម្ពុជា និងសមាគមវៀតណាមនៅកម្ពុជា។

បន្ទាប់ពីលោក ហ៊ុន សែន បានបណ្តេញគណបក្សប្រឆាំង (CNRP) មុនការបោះឆ្នោតសកលឆ្នាំ ២០១៨ លោកបានបើកផ្លូវឱ្យគណបក្សកាន់អំណាច (CPP)គ្រប់គ្រងប្រទេសកម្ពុជាទាំងស្រុង។ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ឲ្យកូនប្រុសគឺលោកហ៊ុនម៉ាណែត តែងតាំងដោយគណបក្សឲ្យធ្វើជានាយករដ្ឋមន្ត្រីនៅឆ្នាំ២០២៣ ដោយបំពានរដ្ឋធម្មនុញ្ញកម្ពុជា ដែលនាយករដ្ឋមន្ត្រីត្រូវតែធ្វើជាសមាជិកសភាមុននឹងក្លាយជានាយករដ្ឋមន្ត្រី។ ការបោះឆ្នោតសម្រាប់តំណែងនេះមិនអើពើសមាជិកបក្សផ្សេងទៀតដែលមានអតីតភាពការងារច្រើនជាង។

កាលពីដើមឆ្នាំនេះ រដ្ឋឯកបក្សរបស់កម្ពុជាបានធ្វើការបោះឆ្នោតព្រឹទ្ធសភានៅថ្ងៃទី ២៥ ខែកុម្ភៈ។ លោក ហ៊ុន សែន រក្សាការក្តោបក្តាប់ប្រទេសយ៉ាងតឹងរ៉ឹងដោយតាំងខ្លួនឡើងកាន់អំណាចជាប្រធានព្រឹទ្ធសភា។

វៀតណាមជាប្រទេសកុម្មុយនិស្តមួយដែលគ្មានបក្សប្រឆាំងចាប់តាំងពីបានកាន់កាប់ភាគខាងត្បូងក្នុងឆ្នាំ ១៩៧៥។ វៀតណាមបានជួយបង្កើតគណបក្សប្រជាជនកម្ពុជានៅឆ្នាំ ១៩៧៩ បន្ទាប់ពីការលុកលុយប្រទេសកម្ពុជាបញ្ចប់សម័យប៉ុលពត។ ទោះយ៉ាងណាក៏ដោយសង្គ្រាមរវាងលោក ហ៊ុន សែន ដែលគាំទ្រដោយយោធាវៀតណាម និងអ្នកជាតិនិយមកម្ពុជាបានបន្ត អស់រយៈពេល១០ឆ្នាំរហូតដល់កិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ ១៩៩១។ នៅពេលនោះពិភពលោកទាំងមូលបានថ្កោលទោសវៀតណាមចំពោះការឈ្លានពាន និងដាក់ទណ្ឌកម្មសេដ្ឋកិច្ច។ វៀតណាមយល់ព្រមដកទ័ពចេញ ក្រោយការដួលរលំនៃសហភាពសូវៀត ព្រោះប្រទេសនេះលែងមានលុយ និងគ្រឿងផ្គត់ផ្គង់ដើម្បីផ្តល់មូលនិធិធ្វើសង្គ្រាម។

ឃើញមានទង់ជាតិវៀតណាមបង្ហោះខ្ពស់ៗក្នុងប្រទេសកម្ពុជា ពលរដ្ឋខ្មែរភ័យខ្លាចការឈ្លានពានមួយទៀត ប៉ុន្តែមិនទាន់យល់ពីអ្វីដែលកំពុងកើតឡើងនៅក្នុងប្រទេសរបស់ខ្លួន។



Vietnamese President Meets Cambodian People's Party President Hun Sen in Phnom Penh, July 12, 2024

វៀតណាមបានបន្សល់ទុកនូវកណ្តាប់ដៃដែកដល់លោក ហ៊ុន សែន និងការិយាល័យនយោបាយកុម្មុយនិស្តរបស់គាត់ បានចូលរួមក្នុងការបោះឆ្នោតដោយសេរី និងយុត្តិធម៌ជាលើកដំបូងរបស់ប្រទេសកម្ពុជាក្នុងឆ្នាំ ១៩៩៣ ដែលគ្រប់គ្រងដោយអង្គការសហប្រជាជាតិ។ មិនយូរប៉ុន្មានទេ លោក ហ៊ុន សែន បានកម្ចាត់អ្នកប្រជាធិបតេយ្យ ដែលជាគូបដិបក្ខទាំងអស់ គឺព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ និងលោក សម រង្ស៊ី។ បីទស្សវត្សរ៍ក្រោយមក ប្រទេសកម្ពុជាឥឡូវនេះស្ថិតនៅក្នុងកណ្តាប់ដៃលោក ហ៊ុន សែន និងសម្ព័ន្ធមិត្តរបស់គាត់ គឺបក្សកុម្មុយនិស្តវៀតណាម។

ប្រធានបក្សកុម្មុយនិស្តវៀតណាម លោក តូ ឡាំ ជារដ្ឋមន្ត្រីវៀតណាមម្នាក់ក្នុងចំណោមរដ្ឋមន្ត្រីវៀតណាម ដែលមកទស្សនកិច្ចនៅកម្ពុជាចុងក្រោយគេក្រោយការរំលាយគណបក្សប្រឆាំង។ ក្នុងនាមជាគណបក្សកាន់អំណាចតែមួយគត់នៅកម្ពុជា និងបាន"ជំពាក់គុណ

តទៅទំព័រទី១៣

# Is Vietnam Gearing Up For Geopolitical Control of Southeast Asian Nations?

From Front Page

Sihamuni, Cambodia's ruling party (CPP) President Hun Sen, Cambodian National Assembly Khuon Sudary, and Vietnamese associations in Cambodia.

After Hun Sen ousted the opposition party (CNRP) ahead of the general election in 2018, he cleared the way for the ruling party (CPP) to take full control of Cambodia. Prime Minister Hun Sen then had his son Hun Manet appointed by the party to be prime minister in 2023, violating the Cambodian constitution in which a prime minister must previously serve as a member of parliament prior to becoming a prime minister. The election for the position ignored other party members with more seniority.

Earlier this year, Cambodia's one-party state held a Senate election on February 25. Hun Sen maintains a tight grip on the country by inserting himself back in power as Senate President.

Vietnam is a communist country without opposition since it took over the South in 1975. Vietnam helped created Cambodia People's Party in 1979 after the invasion of Cambodia that ironically put an end to Pol Pot era. However, the war between Hun Sen who was backed by Vietnam's military and Cambodian nationalists went on for 10 years until the Paris Peace Accord Agreement in 1991. At the time, the whole world condemned Vietnam for the invasion and put sanction on its economy. Vietnam agreed to withdraw its troops only after the fall of the Soviet Union because it no longer had money and supplies to fund the war.

Watching Vietnamese flags flying high in Cambodia, the Cambodian citizens are scared of another invasion but have yet to understand what is happening in their own country.

Vietnam left behind an iron fist with Hun Sen and his communist politburo, who participated in Cambodia's first free and fair election in 1993, supervised by the United Nations. It wasn't long until Hun Sen got rid of all his opponent democrats, Prince Norodom Ranarith and Sam Rainsy. Three decades later, Cambodia is now at the hands of Hun Sen and his friendly ally, the Communist Party of Vietnam.

The President of Vietnam's Communist Party, To Lam, is one of many frequent Vietnamese ministers visiting Cambodia lately after the dissolution of the opposition party. Being the only ruling party in Cambodia and having "owed its birth" to Vietnam, the Cambodian puppet government has erected a Cambodia-Vietnam friendship monument in every province throughout the country.

The Vietnamese President's recent visits involved asking Cambodian People Party President Hun Sen to gear up the legislative ties between the countries. They signed an agreement in November 2022, and organized the first Cambodia – Laos – Vietnam (CLV) Parliamentary Summit in December 2023.

With these meetings, Vietnam has orchestrated what they referred as "inter-parliamentary forums like the ASEAN Inter-Parliamentary Assembly (AIPA), the Inter-Parliamentary Union (IPU), and the Asia-Pacific Parliamentary Forum (APPF)," according to the Vietnamese state newspaper. However, the model framework of their inter parliamentary forums function more like the Eurasian Economic Union where Russia controls all its neighboring countries. In another word, Vietnam has created a mini Soviet Union in Southeast Asia and the world does not know it. Despite their messages of "friendship and collaboration," by using the inter-parliamentary assemblies,

Please see /13

តមកពីទំព័រទី ០៧

## អន្តោប្រវេសន៍រស់នៅក្នុងកណ្តាប់ដៃ

ក្រុម FN កុំឲ្យឈ្នះបានមតិភាគច្រើនដាច់ខាត(50%) នៅសភាឲ្យខាងតែបានគឺក្រុមឆ្វេង នឹងកណ្តាលត្រូវតែជួបចរចាគ្នា។ច្បាប់បោះឆ្នោតស្រុកបារាំងនិយាយថា បេក្ខជនណាបានទទួលលទ្ធផលលើស១២,៥%អាចបន្តរទៅប្រជែងនៅជុំទី២ទៀតបានដូច្នេះមិនមែនមានតែ២នាក់ទេដែលប្រគួតគ្នាជាចុងក្រោយនៅជុំទី២ទេ ដូច្នេះពេលខ្លះមានប្រកួត៣នាក់ក៏មាន(ត្រីកោណ) តំបន់ខ្លះក៏មានបេក្ខជន៤នាក់ប្រកួតគ្នានាជុំទី២... ការចរចាគ្នា បានផលយ៉ាងនេះ គឺគេមិនចរចាជាមួយក្រុម FN ទេ ប៉ុន្តែនៅតំបន់ត្រីកោណ បេក្ខជនខាងឆ្វេង នឹងកណ្តាល មិនប្រកួតគ្នាទេ គឺមានបេក្ខជនម្នាក់ត្រូវដកខ្លួនចេញ ទុកឲ្យបេក្ខជនម្នាក់ទៀតប្រកួតជាមួយនឹងក្រុម FN ហើយករណីត្រីកោននោះមានរហូតដល់ទៅជាង៣០០តំបន់។ គម្រោងនេះគិតថារារាំងក្រុមFNមិនឲ្យបានឈ្នះលើស៥០% តែប៉ុណ្ណោះ ស្មានមិនដល់ថាប្រជាពលរដ្ឋបារាំងក៏បារម្មពីក្រុម FN ច្រើនជាងចិត្តខឹងនឹងប្រធានាធិបតី ម៉ាក្រុង ហើយមានពលរដ្ឋ៦៧%បានចេញទៅបោះឆ្នោតឲ្យក្រុមឆ្វេងនិយមបានលេខ១,លេខ២គឺក្រុមកណ្តាលខាងរដ្ឋាភិបាល រីឯក្រុម FN វិញធ្លាក់ទៅលេខ៣ គ្មានក្រុមណាឈ្នះដាច់បានដល់៥០%ទេ ដូច្នេះ FN នៅសល់តែការខកចិត្ត នឹងវិប្បដិសារី តែប៉ុណ្ណោះ មិនបានរៀបខ្លួនចូលរដ្ឋាភិបាលដូចគ្រោងទុកផងទេ។

មេរៀន?គឺខ្ញុំជឿតែទៅលើសំណាងមិនបានទេ! ខំតែភ័យ ថា«ក្រុមកាចសាហាវដល់ទៅ២ អាចបង្ករគ្រោះថ្នាក់ដល់ជនអន្តោប្រវេសន៍ ដូចរូបខ្ញុំ ដែលមកជ្រកកោននៅស្រុកបារាំងនេះ» ហេតុនេះហើយបានពលរដ្ឋម្នាក់ៗ ត្រូវពិចារណាពីវាសនារបស់ខ្លួន នឹងក្រុមគ្រួសារ ថា«តើក្រុមណាគួរតែឈ្នះ? នៅពេលបោះឆ្នោតម្តងៗ» វាសនារបស់អ្នកបិតនៅលើសម្លេងឆ្នោត១សន្លឹករបស់អ្នកសោះ អ្នកនឹងដឹងថា«ពេលណាដែលគួរភ័យហើយគេត្រូវធ្វើអ្វីខ្លះ?»ឬក៏«ពេលណាដែលគេត្រូវរីករាយ ពីព្រោះតែអ្នកបានឈ្នះនូវអ្វី ដែលអ្នកបានប៉ងប្រាថ្នា» គ្មានឲ្យ«សំណាង»មកសម្រេចវាសនាយើងទៀតទេ៕

## Immigrants In The Hands of Politicians

From Page 07

victory over sending Jordan to Martinhong, or three years later they send each other to the Palace of Elizabeth ... finished French immigrants like me, I have no way to prevent jordan from becoming prime minister! But a new event has taken place: left-wing and left-wing extremists are also afraid to see the Front National goes to Martinhong.

Therefore, a new way to prevent the National Front from winning an absolute majority (50%) in the National Assembly, the left and center must meet to negotiate. French election law says that any candidate who gets more than 12.5% of the vote can advance to the second round, so not just two of the finalists will face each other in the second round,

sometimes there is a contest. There are also 3 (triangles) in some areas, there are also 4 candidates competing in the second round ...

The result of this negotiation was that they did not negotiate with the Front National party,but in the triangle, the left and center candidates did not compete, one candidate had to withdraw, leaving the other candidate to compete with the Front National party, and in the case of the Triangle there are up to more than 300 areas. The plan is thought to have prevented the Front National party from winning more than 50% of the vote. It was unpredicted that French citizens are also worry about Front National party rather than mad at Macron. And 67% of the people went to the polls to vote for the left, the second, the center of the government, while the Front National fell to third, with no team winning 50%.

So, the Front National was disappointed and remorse for not prepare to join the government as planned. Lessons learnt? I can't only believe in luck! I fear that "two vicious groups can endanger immigrants like me who came to take refuge in France," so every citizen must consider their fate and family "which group should win? In each election » Your destiny rests on one of your votes.

You will know, "when to be afraid and what to do?" Or "when they are happy because you have won what you have wished for" no more "luck" to decide our fate.








# ឌណាល ត្រាំ រងការបាញ់ប្រហារនៅវីលរ៉ូគីរដ្ឋផេនស៊ីវេនា

អឺរ៉ុប ថ្ងៃទី១៥កក្កដា២០២៤

នៅរសៀលទី១៣កក្កដា ប្រមាណម៉ោង១៨ជាង នៅទីប្រជុំមីទីងឃោសនារបស់លោកអតីតប្រធានាធិបតី ឌណាល ត្រាំ នៅវិលរ៉ូគី ខ្មាន់កាំភ្លើងម្នាក់ បានលបបាញ់សំខៅលោក ត្រាំ ដោយប្រើកាំភ្លើងស្វ័យប្រវត្តិ AR-15 ពីលើដំបូលផ្ទះមួយ ចម្ងាយប្រមាន២០០ម ពីគោលដៅ សំខាន់បាញ់មួយប្រាវដំបូង គេឃើញស្នាមគ្រាប់បានបញ្ឆិតលើថ្ពាល់ រួចរត់ទៅប៉ះត្រចៀកស្តាំលោក ត្រាំ ទៀត







Nikki Haley

គ្រាប់បានបាញ់មកមួយប្រាវទៀត តែលោកត្រាំបានក្រាបរួចទៅហើយ ពេលភ្លាមនោះនៅជុំវិញលោកត្រាំមានមនុស្សស្លាប់ម្នាក់នឹងរបួស២នាក់ទៀតជាមួយដែរ។ តែគេដឹងថា យុវជនខ្មាន់កាំភ្លើងនោះឈ្មោះថម៉ាស់ម៉ាជូគ្រូកអាយុ២០ឆ្នាំ ត្រូវបានកងសន្តិសុខបាញ់សម្លាប់ជាបន្ទាន់ដែរ, គ្រូក គឺជាយុវជនស្បែកស សមាជិកគណបក្សសាធារណរដ្ឋអាមេរីកាំង ដែលមកចូលរួមប្រជុំនឹងគេដែរ តែនៅពុំទាន់រកឃើញ នូវមូលហេតុដែលនាំឲ្យមានការប៉ងបាញ់សម្លាប់លោកត្រាំ នៅឡើយទេ។

លោកត្រាំ បានត្រូវគេជន្លៀសចេញពិវេទិការកន្លែងកើតហេតុភ្លាម តែលោកត្រាំ ឆ្លៀតលើកកណ្តាលដៃ ឲ្យសារមកថា«ប្រយុទ្ធ ៗ ៗ», បន្តិចមក ពីបន្ទប់ព្យាបាលលោក ត្រាំ លោកបានបញ្ចេញសារមកថា«លោកមិនអីទេ»។ លោកអាចនឹងត្រូវទទួលការតែងតាំងពីគណបក្សសាធារណរដ្ឋរបស់លោក នៅ៣ថ្ងៃក្រោយមក ឲ្យទៅជា«បេក្ខជនប្រធានាធិបតី» នៅរដ្ឋវីកុងស៊ិន ហេតុនេះហើយបានជាការរងរបួសដោយគ្រាប់កាំភ្លើងនេះ ធ្វើឲ្យសមាជិកគណបក្សសាធារណរដ្ឋមានការព្រួយបារម្ភ នឹងបាត់បង់នូវភាពច្បាស់លាស់អស់រលីង បើបាត់បង់លោក ត្រាំ ទៅតើមាននរណាមកឈរឈ្មោះជំនួស។ ភ្លាមៗនោះ សារលោក ដោបាយដិន បានចេញផ្សាយមកថា«ទំនាស់នយោបាយនៅសហរដ្ឋអាមេរីក គឺសម្រេចដោយការបោះឆ្នោត មិនត្រូវឲ្យមានការប្រើហឹង្សាកើតឡើងបានទេ» រីឯមេដឹកនាំឯទៀតៗ មានចិននឹងរុស្ស៊ី ក៏បញ្ចេញប្រតិកម្មជូនពរជាមិត្រភាព




ខុសៗគ្នាមកបន្តជាបន្ទាប់ដែរ។ ឯខាងមេដឹកនាំខាងគណបក្សសាធារណរដ្ឋខ្លះ បានចោទប្រកាន់ខ្លាំងៗមកលើលោក ជោ បាយដិន ថាជាអ្នកនៅពីក្រោយ ការបាញ់ប្រហារលោកត្រាំ តែខាងគណបក្សប្រជាធិបតេយ្យលោក បាយដិន ពុំបានតបតអ្វីទេ។

គេនៅចងចាំនៅឡើយថា ការប៉ុនប៉ងសម្លាប់អតីតប្រធានាធិបតីអាមេរិកាំងនោះ មិនមែនជាលើកដំបូងនោះទេ គឺមានលោក រ៉ូណាល រ៉េគ្ហាន់ ដែលត្រូវគេបាញ់ ដោយកាំភ្លើងខ្លី នៅទីប្រជុំជនបណ្តាលឲ្យរបួសជាទម្ងន់ តែមិនស្លាប់ទេ, មុននោះបន្តិច ក៏មានគេលបបាញ់លោកប្រធានាធិបតី ជេរ៉ល ហ្វ៊ត កាលពីឆ្នាំ១៩៧៥, ហើយមុននោះទៀត ក៏មានគេលបបាញ់លោកប្រធានាធិបតី ជនកេណ្ណឌី នៅពេលទស្សកិច្ចនៅរដ្ឋតិចសាស់ ដល់បានសម្រេច... ទាំងនោះ ពលរដ្ឋសហរដ្ឋអាមេរីក គេចាត់ទុកថា ការកាន់កាភ្លើង ជាសេរីភាពរបស់ពួកគេ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញអាមេរីកាំង, ទៅអនាគត អំពើហឹង្សាកំរឹតកំពូលនោះ ទំនងជាពុំមានធ្វើឲ្យមានការផ្លាស់ប្តូរអ្វីក្នុងច្បាប់នោះទេ។

**សន្និបាទគណបក្សសាធារណរដ្ឋនៅវីលរ៉ូគី**

គណបក្សសាធារណរដ្ឋ បានប្រារព្ធពីធីតែងតាំងបេក្ខជនប្រធានាធិបតីរបស់ពួកគេ ថ្ងៃទី១៧កក្កដា២០២៤ ដោយតែងតាំងលោកឌណាល ត្រាំ ជាបេក្ខជនប្រធានាធិបតីខាងគណបក្សសាធារណរដ្ឋប្រជែងនឹងគណបក្សប្រជាធិបតេយ្យនៅថ្ងៃទី៥វិច្ឆិកា២០២៤ខាងមុខ។ ជាមួយគ្នានោះ បេក្ខជនអនុប្រធានាធិបតីក៏ត្រូវបង្ហាញយ៉ាងគួរឲ្យភ្ញាក់ផ្អើល គឺលោកជេឌី វេនស៍ J.D. Vanse អាយុ៣៨ឆ្នាំ ជាសមាជិកសភារដ្ឋមីនីសីតា ដែលធ្លាប់ពីពត៌នាថា«លោក ត្រាំ ជាមនុស្សផ្តាច់ការណាស៊ី» តែការតែងតាំងនេះ ធ្វើឲ្យលោកវែនស៍ក្លាយជា បេក្ខជនអនុប្រធានាធិបតីក្មេងជាងគេបង្អស់ ក្នុងប្រវត្តិអនុប្រធានាធិបតីអាមេរីកាំង។

**J.D. Vance បេក្ខជនអនុប្រធានាធិបតីជាមួយ ឌណាល ត្រាំ**

លោក ឌណាល ត្រាំ មិនបានថ្លែងការដោយផ្ទាល់ទេ ជំនួសដោយ នីគី ហៃលី ដោយសារតែឱបត្តិហេតុបាញ់ឲ្យលោករបួស កាលពីថ្ងៃទី១៣មុននេះ, តែលោកបានឲ្យគេប្តូរអត្ថន័យ នៃសុន្ទរកាថា ដែលធ្លាប់តែបំផ្លើសញុះញង់ ឲ្យទៅជាសាររួបរួមជាតិ ដែលកំពុងតែបែកបាក់គ្នា ទៅវិញ គួរឲ្យចម្លែកមែន!៕

# ពិធីបុណ្យប្រជាប្រិយទីក្រុងឡូវែល ឆ្នាំ ២០២៤ ជូនដំណឹងស្តីពីកម្មវិធីសម្តែងតន្ត្រី អាហារ និងសិប្បកម្ម មកពីជុំវិញពិភពលោក ដាក់តាំងបង្ហាញនៅទីក្រុងឡូវែល រដ្ឋម៉ាសាឈូសេត ថ្ងៃទី ២៦-២៨ ខែកក្កដា កម្មវិធីបុណ្យទាំងស្រុងមាននៅទីនេះ

ដោយៈកាសែតខ្មែរប៉ុស្តិ៍សហរដ្ឋអាមេរិក

ពិធីបុណ្យប្រជាប្រិយទីក្រុងឡូវែល ឆ្នាំ ២០២៤ ត្រូវបានកំណត់សម្រាប់ពិធីបុណ្យរយៈពេលបីថ្ងៃចាប់ពីថ្ងៃទី ២៦-២៨ ខែកក្កដា។ វានឹងចាប់ផ្តើមនៅម៉ោង ៦:១៥ ល្ងាចថ្ងៃសុក្រ ទី ២៦ ខែកក្កដា ជាមួយនឹងក្បួនដង្ហែទង់ជាតិប្រពៃណីដែលធ្វើឡើងដោយប្រជាពលរដ្ឋក្នុងតំបន់ដែលមកពីជុំវិញពិភពលោក។ នៅឆ្នាំនេះ Jorge Arce Comparsa Boricua នឹងដឹកនាំក្បួនដង្ហែរតាមដងផ្លូវនៃទីប្រជុំជន ទីក្រុងឡូវែល រដ្ឋម៉ាសាឈូសេត ទៅកាន់កន្លែងពិធីបើកនៅឧទ្យាន ប៊ដឌីងហោស (Boaring House Park) ។

ក្នុងរយៈពេលបីថ្ងៃចុងសប្តាហ៍ មហោស្រពលើកទី ៣៧ នឹងបង្ហាញសិល្បករលំដាប់ពិភពលោកជាង ២០ រូបដែលសំដែងតន្ត្រី និងរបាំប្រពៃណីជាច្រើន មកពីប្រទេសកូរ៉េ និងរដ្ឋ លុីស៊ីអាណា (Louisiana) សម្តែងនៅលើឆាកទូទាំងទីក្រុងឡូវែល។ ព័ត៌មានបន្ថែម រួមទាំងកម្មវិធីទាំងស្រុងនៃការសម្តែងសកម្មភាព សិប្បកម្ម និងអាហារដែលតំណាងឱ្យមុខម្ហូបមកពីជុំវិញពិភពលោក មាននៅលើគេហទំព័រ lowellfolkfestival.org។

នាយកមហោស្រពលោក Lee Viliesis បានមានប្រសាសន៍ថា "ឆ្នាំនេះ មហោស្រពមានក្តីរំភើបរីករាយក្នុងការប្រកាសពីទីតាំងសម្តែងតាមដងផ្លូវថ្មីរបស់ខ្លួននៅកាច់ជ្រុងផ្លូវ សង់ត្រាល់ (Central) និងផ្លូវ មឺរីម៉ាក់ (Merrimack)"។ "នឹងមានបន្ថែមកម្មវិធីសម្តែងដែលនឹងនាំមកនូវភាពរស់រវើកថ្មីពាសពេញទីប្រជុំជន"។

អ្នកសំដែងតាមដងផ្លូវនៅថ្ងៃសៅរ៍ សំដែងដោយក្រុមសិល្បៈ San Simón Caporales មកពី New England ដែលសំដែងរបាំប្រពៃណីប្រទេស បូលីវី និងក្រុមសំដែង StiggityStackz Worldwide ដែលជាក្រុមរាំបែបសេរីដែលល្បីល្បាញរបស់ បូស្តុន។

នៅថ្ងៃអាទិត្យ នៅតាមកាច់ជ្រុងផ្លូវ Merrimack និងផ្លូវ Central នឹងមានការសម្តែងដោយក្រុមសិល្បៈ Yo-Yo Guy ផ្ទាល់របស់ New England ដែលជាអ្នកឈ្នះពានរង្វាន់ Grand Prix របស់សហព័ន្ធអន្តរជាតិ Yo-Yo និងជាអ្នកទទួលកំណត់ត្រាពិភពលោក ហ្គីននីស (Guinness) ចំនួន ៤ ដែលសម្តែងបានល្អបំផុតបែបកំប្លែងថាមពល Veronica Robles ប្រធាន និងជាស្ថាបនិកនៃមជ្ឈមណ្ឌលវប្បធម៌ Veronica Robles នៅបូស្តុនខាងកើត និងក្រុមតន្ត្រី Mariachi របស់គាត់ និងវិទ្យាស្ថានសិល្បៈកូរ៉េ ក្រុមសម្តែងរបស់ទីក្រុង ស៊ីកាហ្គោ (Chicago) ក្នុងសំលៀកបំពាក់ចម្រុះពណ៌ដ៏អស្ចារ្យ ចម្រៀងដ៏រីករាយ ការរាំ និងគប់ភ្លើង។

លើសពីនេះ ពិធីបុណ្យទាំងបួននៅឧទ្យាន Boarding House Park ឆាកសម្តែងតាមដងផ្លូវជិតទីផ្សារ Market Street Stage ទីលាន St. Anne's Churchyard និងទីលានសម្តែងរបាំ នឹងមានការសម្តែងដោយតន្ត្រីករ និងអ្នករាំលំដាប់ពិភពលោក ដែលតំណាងឱ្យវប្បធម៌មកពីជុំវិញពិភពលោក និងនៅគ្រប់ទិសទី។

មហោស្រពប្រជាប្រិយទីក្រុងឡូវែល ផ្តល់នូវបទពិសោធន៍ពិសេសៗ ដើម្បីស្តាប់សិល្បករក្នុង មហោស្រពពីប្រវត្តិវប្បធម៌ចម្រុះស្វែងយល់ពីទំនាក់ទំនងភាពស្រដៀងគ្នា និងភាពខុសគ្នានៅក្នុងដំណើរតន្ត្រីរបស់ពួកគេ។ វគ្គសន្ទនា/ការសម្តែងកម្រិតមធ្យមទាំងនេះអនុញ្ញាតឱ្យអ្នកចូលរួមពិធីបុណ្យមានទំនាក់ទំនងកាន់តែជិតស្និទ្ធជាមួយតន្ត្រីករ។

នៅថ្ងៃសៅរ៍ អ្នកសំដែងនៃគ្រួសារ Choro das 3 ក្រុមសម្តែង The Friel Sisters និង Eddie Pennington & Caleb Coots នឹងចូលរួមក្នុងវគ្គមួយដែលមានចំណងជើងថា ទាំងអស់គ្នានៅក្នុងគ្រួសារតែមួយ (All in the Family) ។ សម្តែង

តទៅទំព័រទី១៥

# 2024 LOWELL FOLK FESTIVAL ANNOUNCES FULL PERFORMANCE SCHEDULE

## Music, Food, and Crafts from Around the World Showcased Throughout Lowell, MA July 26-28 Complete Festival Schedule Here

**By Khmer Post USA**

2024 Lowell Folk Festival is set for a three days festival from July 26-28. It will kick off at 6:15pm on Friday July 26th with the traditional Parade of Flags carried by local citizens who hail from around the world. This year Jorge Arce Comparsa Boricua will lead the Parade through the streets of downtown Lowell, MA to the opening ceremony at Boarding House Park.



Over three days weekend, the 37th edition of the Festival will present more than 20 world-class artists performing music and dance traditions that range from Korea to Louisiana, on stages throughout Lowell. More information, including a complete schedule of performances, activities, crafts, and food stands representing cuisines from around the world, is available at lowellfolkfestival.org.

"This year the Festival is excited to announce its new street performance location at the corner of Central and Merrimack Streets," said Festival Director Lee Viliesis. "There will be an expanded schedule of performances that will bring new vitality to the furthest corners of downtown."

Saturday's street performers will be San Simón Caporales of New England, who perform traditional Bolivian dance, and StiggityStackz Worldwide, Boston's acclaimed freestyle dance troupe.

On Sunday, the corner of Merrimack and Central Streets will be lit up with performances by New England's own Yo-Yo Guy, a past winner of the International Yo-Yo Federation's Grand Prix and holder of 4 Guinness World Records, who performs his high-energy comedy show; Veronica Robles, director and founder of the Veronica Robles Cultural Center in East Boston, and her Mariachi Band; and the Korean Performing Arts Institute of Chicago's flying footwork, brilliantly colored dress, joyful song, dance and percussion.

In addition, the four festival stages; Boarding House Park, Market Street Stage, St. Anne's Churchyard, and the Dance Pavilion, will feature performances by world-class musicians and dancers representing cultures from around the world, and around the corner.

The Lowell Folk Festival provides unique experiences to hear Festival artists from diverse cultural backgrounds explore the connections, similarities, and differences in their musical journeys. These moderated talk/demonstration sessions allow festivalgoers a more intimate interaction with the musicians.

On Saturday, the familial performers of Choro das 3, The Friel Sisters,

Please see /15



តមកពីទំព័រទី ០៩

# តើវៀតណាមត្រៀមលក្ខណៈគ្រប់

កំណើត" ដល់ប្រទេសវៀតណាម រដ្ឋាភិបាលអាយ៉ងកម្ពុជាបានសាងសង់ស្តូបមិត្តភាពកម្ពុជា-វៀតណាម នៅគ្រប់ខេត្តទូទាំងប្រទេស។

ដំណើរទស្សនកិច្ចរបស់ប្រធានាធិបតីវៀតណាមនាពេលថ្មីៗនេះ ពាក់ព័ន្ធនឹងការស្នើឲ្យប្រធានគណបក្សប្រជាជនកម្ពុជា លោកហ៊ុនសែន ពង្រឹងទំនាក់ទំនងនីតិបញ្ញត្តិរវាងប្រទេសទាំង ពីរ។ ពួកគេបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយនៅក្នុងខែវិច្ឆិកា ឆ្នាំ ២០២២ និងបានរៀបចំកិច្ចប្រជុំកំពូលសភាកម្ពុជា-ឡាវ-វៀតណាម (CLV) លើកដំបូងនៅខែធ្នូ ឆ្នាំ ២០២៣។

ជាមួយនឹងកិច្ចប្រជុំទាំងនេះវៀតណាម កុម្មុយនិស្តវៀតណាម នឹងមិនត្រឹមតែបើកកិច្ចប្រជុំប្រចាំឆ្នាំក្នុងចំណោមរដ្ឋមន្ត្រីសន្តិសុខសាធារណៈ/ផ្ទៃក្នុង និងការពារប្រទេសទាំងបីប៉ុណ្ណោះទេ ប៉ុន្តែពួកគេនឹង "ធ្វើសមយុទ្ធរួមគ្នា ក្នុងការឆ្លើយតបទៅនឹងបញ្ហាប្រឈមផ្នែកសន្តិសុខមិនប្រពៃណី"។ ប្រទេសទាំងបីបានបើកសន្និសីទប្រចាំឆ្នាំលើកទី ១ របស់រដ្ឋមន្ត្រីសន្តិសុខសាធារណៈ និងកិច្ចការផ្ទៃក្នុង កាលពីថ្ងៃទី ២៩ ខែមីនា ឆ្នាំ ២០២៤ នៅទីក្រុង ដាណាង ។

មេដឹកនាំទាំងពីរបានឯកភាពធ្វើកំណែទម្រង់វិស័យអប់រំ និងទំនាក់ទំនងនៅកម្ពុជា ដើម្បីជំរុញការទទួលយកជាសាធារណៈនូវ "មិត្តភាព សាមគ្គីភាព



Vietnamese President To Lam and President of the Cambodian National Assembly Khuon Sudary. Photo via VNA

និងកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យ" ជាមួយវៀតណាម។ កិច្ចសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយនៅទីនេះមានន័យថា ជាដំបូងពួកគេនឹងជួបជាមួយថ្នាក់ដឹកនាំសភា រដ្ឋមន្ត្រីសន្តិសុខសាធារណៈ ការពារជាតិ និងកិច្ចការបរទេស រួមជាមួយនឹងថ្នាក់ដឹកនាំក្រសួង និងវិស័យមួយចំនួនទៀត មិនកំណត់ចំពោះ អាជីវកម្ម ការអប់រំ និងអ្វីៗជាច្រើនទៀត។

នៅចំពោះមុខនោះលោកប្រធានាធិបតី តូ ឡាំ បានផ្តល់ប្រាក់ចំនួន ២ម៉ឺនដុល្លារ ដល់អង្គការមិនរកប្រាក់ចំណេញវៀតណាម នៅកម្ពុជា ដើម្បីសាងសង់សាលារៀន សម្រាប់កុមារវៀត ណាមនៅកម្ពុជា។ លោកក៏បានស្នើឲ្យប្រធានគណបក្សប្រជាជនកម្ពុជា លោក ហ៊ុន សែន បង្កើតលក្ខខណ្ឌអាជីវកម្មអំណោយផលសម្រាប់ជនជាតិវៀតណាម។ បច្ចុប្បន្ន វៀតណាមមានផ្ទៃដីជិតកន្លះលានហិកតារួចហើយពីសម្បទានដីចំនួន ៥៥ នៅកម្ពុជា។ តាមរយៈដីសម្បទានទាំងនេះ មិនសូវមានផលប្រយោជន៍អ្វីដល់អ្នកភូមិ មន្ត្រីរដ្ឋាភិបាលពុករលួយ និង មន្ត្រីយោធាក្នុងប្រទេសវៀតណាមមានការឃុបឃិតគ្នាក្នុងការជួញដូរឈើប្រណីតពីឧទ្យានជាតិ

តទៅទំព័រទី១៥

បានរៀបចំនូវអ្វីដែលគេហៅថា "វេទិកាអន្តរសភាដូចជា អន្តរសភាអាស៊ាន (AIPA) សហភាពអន្តរសភា (IPU) និងវេទិកាសភាអាស៊ីប៉ាស៊ីហ្វិក (APPF)"។ កាសែតរដ្ឋវៀតណាម។ ទោះជាយ៉ាងណាក៏ដោយ ក្របខ័ណ្ឌគំរូនៃវេទិកាអន្តរសភារបស់ពួកគេមានមុខងារច្រើនជាងសហភាពសេដ្ឋកិច្ចអាស៊ីអឺរ៉ុប (Eurasian) ដែលរុស្ស៊ីគ្រប់គ្រងប្រទេសជិតខាងទាំងអស់។ ម្យ៉ាងទៀត វៀតណាមបានបង្កើតសហភាពសូវៀតខ្នាតតូចមួយនៅអាស៊ីអាគ្នេយ៍ ហើយពិភពលោកមិនស្គាល់វាទេ។ ថ្វីត្បិតតែមានសារនៃ "មិត្តភាព និងកិច្ចសហប្រតិបត្តិការ"របស់ពួកគេ ដោយប្រើសភាអន្តរសភាវៀតណាមមានបំណងគ្រប់គ្រងតំបន់អាស៊ីអាគ្នេយ៍ដែលនៅសល់។

យោងតាមកាសែតរដ្ឋវៀតណាម លោក ហ៊ុន សែន និងសម្ព័ន្ធមិត្តគឺបក្ស

# Is Vietnam Gearing Up For Geopolitical Control of Southeast Asian Nations?

From Page 09

Vietnam aims to control the rest of Southeast Asia.

According to the Vietnamese State-owned newspaper, Hun Sen and his ally, the Communist Party of Vietnam, will not only hold annual meetings among the ministers of public security/interior, and defenses of the three countries, but they will do "joint exercises in response to non-traditional security challenges." The three counties held the 1st Annual Conference of Ministers of Public Security and Home Affairs in March 29, 2024 in Da Nang city.

The two leaders agreed to reform the education and communication in Cambodia to bolster public acceptance of "friendship, solidary, and comprehensive cooperation" with Vietnam. The comprehensive cooperation here means they first will have meetings with parliamentary leaders, ministers of public security and national defense and foreign affairs, along with leaders of some other ministries and sectors not limited to business, education and more.

On that front, President Lam gave $20,000 to the Vietnamese non-profit in Cambodia to build schools for Vietnamese children in Cambodia. He also asked the Cambodian People's Party President Hun Sen to create favorable business conditions for the Vietnamese. Currently, Vietnam already has nearly half a million hectares from 55 land concessions in Cambodia. Through these land concessions, which had very little to no benefit for the villagers, corrupted governmental officials and military personnel in Vietnam are complicit in trafficking luxury timber from Cambodia National Parks and pocketed millions of dollars in bribes from the smugglers, as reported by the environmental investigation agency.

Vietnam established the Cambodia-Laos-Vietnam (CLV-Triangle Area Development) Agreement in 1999 which involved 10 provinces and later increased to 13 provinces between the three countries and aimed to promote economic connectivity along the border.

Under this development pretext, many Cambodian experts have raised their concerns that Cambodia will lose its sovereignty. Many Cambodians think it's a small matter because the development will be only in border provinces, but little do they know that Vietnam intends to have the Vietnamese people live and work freely without visas, trading that is controlled by Vietnam, schools teaching Vietnamese language and culture, and promoting friendship with Vietnam throughout the entirety of Cambodia and Laos.

Recently, Vietnam built a new National Assembly Building in Cambodia which cost $25 million and will be opening soon, according to the President of the Cambodian National Assembly, Khuon Sudary. In Laos, Vietnam also built a New National Assembly building, parliamentary office, and several other buildings for education and culture that cost nearly $300 million. With this inter-parliamentary forum, Cambodia has 17 million people, Laos has 7.5 million people, Vietnam has 98 million people. When it comes to voting, it's 1 Cambodian to 5.7 Vietnamese. There will be no power for Cambodia or Laos.

The friendship with Vietnam is heavily protected by Hun Sen. Any criticism will result in prison time. A student, Thel Theland, who spoke against the University of Phnom Penh for implementing Vietnamese language, was arrested and imprisoned for over a year.

A Cambodian think tank in the US said "with this inter-parliamentary forum under guise of friendship and cooperation, we will see everything published in three languages, Cambodian, Vietnamese, and Laos. Vietnam claims it's like IEU, (Inter-Parliamentary Union) which similar to UN but the members are the current member of parliament and their budget is limited and it is completely like an association. This is worse than that. Here Vietnam will have the control of everything from education to business to culture and politics. Cambodia and Laos lose their sovereignty."

តមកពីទំព័រទី ០៨

## ជំនន់ទឹកភ្លៀងនៅរាជធានីភ្នំពេញ...

ទប់ទឹកកុំឲ្យហូរចូលផ្ទះទោះបីភ្លៀងឈប់ធ្លាក់ពីរថ្ងៃមកហើយក្តី តែតំបន់ខ្លះនៅតែបន្តរងនូវការជន់លិចដដែល ជុំវិញរឿងនេះអភិបាលរាជធានីភ្នំពេញ លោក ឃួង ស្រេង បាន ប្រាប់យ៉ាងខ្លីថាលោកកំពុងជាប់រវល់ដើម្បីដោះស្រាយបញ្ហានេះ " ប៉ុន្តែខ្ញុំកំពុងដំណើរការប្រញ៉ាប់ហាសប្រញ៉ាប់ជាងក្មួយឯង ដើម្បីដោះស្រាយបញ្ហាជូនប្រជាជនខ្ញុំ អរគុណច្រើនក្មួយហាស!"តាមការចុះផ្សាយរបស់ទូរទស្សន៍ជាតិ នៅថ្ងៃទី០៩ ខែកក្កដា បានឲ្យដឹងថាសាលារាជធានីភ្នំពេញមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ កំពុងរៀបចំដាក់ប្រព័ន្ធលូធំៗ មានទទឹងចាប់ពីមួយម៉ែត្រកន្លះរហូតដល់ខ្លះមានទទឹងពីរម៉ែត្រកន្លះ ដើម្បីរំដោះការជន់លិចដោយទឹកភ្លៀង ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ បន្ថែមពីនេះការស្តារស្ថានីយបូមទឹកតាម ចំណុចសំខាន់សំខាន់ដែលមានកម្លាំងម៉ូទ័រអាចបូមបានច្រើនម៉ែត្រគូបឲ្យទណ្ណកម្រិតទឹកភ្លៀងដើម្បីបញ្ចៀសការជន់លិចនៅតាមដងផ្លូវ នៅតាមតំបន់មួយចំនួនដែលទឹកមិនទាន់ស្រកដូចជានៅតំបន់នៅក្នុងខណ្ឌឫស្សីកែវ រដ្ឋបាលខណ្ឌ បានប្រើប្រាស់ឡានបូមទឹកលូកាយកាកសំណល់ ចេញពីមាត់លូ និងស្តារព្រែកអូរតាវែង ដើម្បីឲ្យទឹកឆាប់ហូអស់ បច្ចុប្បន្នរដ្ឋបាលរាជធានីភ្នំពេញ និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុនហៅ Jica កំពុងតែសហការគ្នាសិក្សាអំពីលទ្ធភាពនៃការអនុវត្តគម្រោងការពារទឹកជំនន់ និងការកែលម្អប្រព័ន្ធប្រឡាយដំណាក់កាលទី៥ ដែលគ្របដណ្តប់លើភាគនិរតីនៃរាជធានីភ្នំពេញ ដើម្បីដោះស្រាយបញ្ហាជំនន់ទឹកភ្លៀងនារដូវវស្សា ខណៈប្រឡាយបឹងបួមួយចំនួននៅក្នុងតំបន់នេះត្រូវបានចាក់ដីលុបដើម្បីអភិវឌ្ឍ សង់លំនៅស្ថាន នៅក្នុងគម្រោងចំនួន០៩កន្លែង របស់ជប៉ុន បានចំណាយប្រាក់សរុបប្រមាណជាង១១០លានដុល្លារ តែយ៉ាងណាប្រជាពលរដ្ឋនៅរាជធានីភ្នំពេញ តែងតែរិះគន់ថាបច្ចេកទេសរៀបចំប្រព័ន្ធលូហាក់គ្មានគម្រោងគូរវាស់ ឬក៏វាស់វែងឲ្យបានច្បាស់លាស់នោះឡើយ ជារឿយៗគេតែងតែឃើញអាជ្ញាធរគាស់ផ្លូវដើម្បីដាក់លូ ឬក៏ធ្វើផ្លូវហើយទើបដាក់លូតាមក្រោយរហូតដល់មានពាក្យចំអកថាកាយផ្លូវដាក់លូដាក់លូកាយផ្លូវជាដើម ទាក់ទិននឹងរឿងនេះមន្ត្រីសម្របសម្រួលគម្រោង នៃគម្រោងបណ្តាញយុវជនកម្ពុជា CYN លោក អូត ឡាទីន បាន លើកឡើងថារដ្ឋាភិបាលនៅមានកម្រិតនៅក្នុងការធ្វើតាមការប្តេជ្ញាចិត្តរបស់ខ្លួនដើម្បីបញ្ចៀសទឹកជំនន់នៅក្នុងរាជធានីភ្នំពេញ ដោយសារតែការលិចលង់នៅតែបន្តកើតមាននៅពេលភ្លៀងធ្លាក់ លោក



ជំនន់ទឹកភ្លៀងធ្វើឲ្យផ្លូវនៅទីក្រុងភ្នំពេញលិចស្ទើរតែទាំងស្រុង

មើលឃើញថាបញ្ហានេះបណ្តាលមកពីកត្តាច្រើនរួមផ្សំគ្នា ដោយក្នុងនោះរួមទាំងមានការទុកដាក់សំរាម មិនបានត្រឹមត្រូវផងដែរ " ខ្ញុំថាចំណុចសំខាន់ទី០១ ហ្នឹងគឺធ្វើយ៉ាងណាបង្កើនទៅលើការរៀបចំប្រព័ន្ធប្រឡាយទឹក រាជធានីភ្នំពេញដោយដកលូតូចៗជំនួសមកវិញធំធំជាពិសេសគឺច្រកផ្លូវទឹកសំខាន់ៗ ហើយចំណុចទី០២រាជរដ្ឋាភិបាល តាមរយៈក្រសួងបរិស្ថាន គឺត្រូវតែធ្វើការងារយ៉ាងសកម្មនៅក្នុងការចុះអប់រំប្រជាពលរដ្ឋ ឲ្យចេះទុកដាក់សំរាមឲ្យបានត្រឹមត្រូវហើយ ចំណុចទី០៣ ទាក់ទងជាមួយនឹងក្រុមហ៊ុនប្រមូលសំរាមហ្នឹង ឃើញថា យ៉ាងណាឲ្យប្រមូលសំរាម ឲ្យបានល្អហើយឲ្យបានទាន់ពេលវេលា ដើម្បីធ្វើយ៉ាងណាបញ្ចាសទៅលើការកកស្ទះនៅពេលដែលមានជំនន់ទឹកភ្លៀង មានទឹកភ្លៀងយើងទៅសំរាមហូរចូលក្នុងលូ ធ្វើអីនោះទាល់តែមានការស្ទះផងគ្រាន់តែម្តង បាទ! " មិនខុសគ្នាទៅហ្នឹងអ្នកលេងតាមបណ្តាញសង្គមថា អោយតែពេលមានភ្លៀងដឹងតែលិច ហើយ ក្រៅពីបញ្ហានេះការលុបបឹងធម្មជាតិក៏ជាកត្តាមួយបណ្តាលឲ្យភ្នំពេញរងការជន់លិចផងដែរ កាលពីអំឡុងខែធ្នូ ឆ្នាំ២០១៩ សមាគមធាងត្នោត ធ្លាប់

តទៅទំព័រទី១៧

## Floods in Phnom Penh Remain a Problem

From Page 08

million dollars is underway to prevent flood in Phnom Penh. However, the people in the capital Phnom Penh have always criticized that the drainage systems do not seem to have a good plan and measurement accurately.

In regard with roads, sewers, sidewalks construction, the project coordinator of the Cambodian Youth Network (CYN) Mr. Ot Latin, said that the government is still limited in fulfilling its commitment to prevent floods in Phnom Penh, because the flooding continues when it rains. He sees that this problem is caused by a combination of factors, including the proper storage of garbage.

"I think the first important point is to increase the arrangement of the canal system in Phnom Penh by removing small sewers and replacing them with big ones, especially the main waterways. The second point, the Royal Government through the Ministry of Environment must work actively in educating people to know how to properly dispose of garbage, and the third point related to the garbage collection company to see how to collect garbage well and on time to release the water when there is a flood and rain."

Social media users say that when rain comes, it floods. Land refill of natural lakes is also a factor that caused Phnom Penh to be flooded during December 2019, this is according to Samakum Teang Tnort's report revealing the serious environmental and social impacts caused by the development of many satellite cities and towns.

Please see /17




CONWAY
INSURANCE AGENCY

រយៈពេល២៥ឆ្នាំ ភ្នាក់ងារធានារ៉ាប់រងខុនវ៉េយបានបម្រើសហគមន៍ដោយធានារ៉ាប់រងគ្រប់មុខប្រកបដោយគុណភាពនៅតំបន់ញូអ៊ីងឡែន ។
យើងខ្ញុំជាភ្នាក់ងារបំពេញសេវាគ្រប់មុខដូចខាងក្រោម :

ការធានារ៉ាប់រងគ្រួសារ
- រថយន្ត
- ផ្ទះ
- ផ្ទះល្វែង
- គ្រឿងអលង្ការ
- វត្ថុសិល្បៈ
- វត្ថុបុរាណ

ការធានារ៉ាប់រងជំនួញ
- អចលនវត្ថុ
- សុវត្ថិភាពជំនួញ (Liability)
- សុវត្ថិភាពជំនាញ (Professional Liability)
- ថៃខូខម (Worker's Compensation)
- បនដស៍ (Bonds)
- អ្នកមើលថែឡាន និងការរក្សាឡាន
- ធានារ៉ាប់រងពិការភាព និងជីវិត
- កម្មវិធីពិសេសផ្សេងៗទៀត

CONWAY INSURANCE AGENCY
77 E. Merrimack Street. Lowell, MA 01852
Tel: 978-454-5054|Fax 978-453-2480
www.conwayinsurance.com
សូមទាក់ទងមក : ហ្វីលីប មុត, អ្នកគ្រប់គ្រង




តមកពីទំព័រទី ១២

## ពិធីបុណ្យប្រជាប្រិយទីក្រុងឡូវែល...

តន្ត្រីឧទ្ទិសដួងព្រលឹង (Soul-full Sounds of Devotion) នាំមកជូនដោយអ្នកចម្រៀង Yoni Battat អ្នកចម្រៀង High Fidelity និង អ្នកចម្រៀង Annie & The Caldwell Singers បង្ហាញពីរបៀបដែលពួកគត្បាញបញ្ចូលធាតុពិសិដ្ឋទៅក្នុងតន្ត្រីរបស់ពួកគេ។

នៅថ្ងៃអាទិត្យ មហោស្រពនេះនឹងរៀបចំវិទិកាចលនាមេ (Masters of Movement) ដែលជាការសន្ទនាអំពីទំនៀមទំលាប់របាំជាមួយអ្នករាំ Kathak



ដ៏ល្បីថ្នាក់អន្តរជាតិ Farah Yasmeen Shaikh អ្នករាំដ៏មានមោទនភាពដើមកំណើតនិងវិទ្យាស្ថានសិល្បៈសំដែងកូរ៉េ នៃទីក្រុងឈីកាហ្គោ។ Joe Hall & the Cane Cutters, Afro Dominicano, Swanky Kitchen Band, និង Cyril Neville នឹងចូលរួមក្នុងវគ្គមួយដែលមានចំណងជើងថា Caribbean Crossroads: ពី Bayou ដល់ Barrio និង Jesse Daniel, Lutchinha និង Sugaray Rayford នឹងនិយាយនិងច្រៀងចម្រៀងអំពីស្នេហា ការបាត់បង់ និងបញ្ហានៅក្នុងវេទិកាមួយដែលហៅថា ចម្រៀងសម្រាប់ពេលវេលាល្អ និងពេលវេលាលំបាក។

Viliesis បានមានប្រសាសន៍ថា "ជារៀងរាល់ឆ្នាំ ចំនុចពិសេសមួយនៃពិធីបុណ្យប្រជាប្រិយទីក្រុងឡូវែល គឺជាជម្រើសអាហារដ៏គួរឱ្យទាក់ទាញសម្រាប់អ្នកស្រលាញ់សិល្បៈប្រជាប្រិយដែលស្រេកឃ្លានគ្រប់វ័យ"។ អាវយឺតមានអក្សរសរសេរថា "ខ្ញុំនៅទីនេះដើម្បីតែអាហារ" មានការពេញនិយមយ៉ាងខ្លាំងកាលពីរដូវស្លឹកឈើជ្រុះឆ្នាំមុន មនុស្សគ្រប់រូបចូលរួម មានក្រុមអាហារដែលចូលចិត្ត ពួកគេត្រលប់មកវិញទៀត ជារៀងរាល់ឆ្នាំ"។

នៅឧទ្យាន Boarding House Park ទីលាន Dance Pavilion និងតាមដងផ្លូវផ្សារ (Market Street) អាហារមកពីជុំវិញពិភពលោកត្រូវបានរៀបចំ និងបម្រើដោយអង្គការមិនរកប្រាក់ចំណេញក្នុងស្រុកដែលតំណាងឱ្យវប្បធម៌ជនជាតិចម្រុះ ដែលមាននៅក្នុងរដ្ឋ New England។ មុខម្ហូបតំណាងឱ្យជនជាតិព័រទុយហ្គាល់ ប្រេស៊ីល ក្រិក ប៉ូឡូញ អាស៊ីឡាទីនអាហ្វ្រិកភូមានិងសហគមន៍ផ្សេងទៀតជាច្រើន ធានាថានឹងមានបទពិសោធន៍ធ្វើម្ហូប និងវប្បធម៌ចម្រុះ។

អ្នកចូលរួមក្នុងមហោស្រពក៏មានឱកាសទទួលបានបទពិសោធន៍សិល្បៈដែលមើលឃើញ និងសិប្បកម្មនៅផ្សារ Experience Lowell Arts Market។ នឹងមានសិល្បករ សិល្បការិនីសិប្បកម្មនិងអង្គការនានាក្នុងតំបន់ចំនួន ៥០ នាក់ ដែលអនុញ្ញាតឱ្យអ្នកចូលរួមពិធីបុណ្យទទួលបានបទពិសោធន៍គ្រប់យ៉ាងដែលសហគមន៍សិល្បៈ និងវប្បធម៌របស់ Mill City មានផ្តល់ជូន៕

## 2024 LOWELL FOLK FESTIVAL ANNOUNCES FULL PERFORMANCE SCHEDULE

From Page 12

and Eddie Pennington & Caleb Coots will take part in a session titled All in the Family. Soul-full Sounds of Devotion brings together Yoni Battat, High Fidelity, and Annie & The Caldwell Singers, to demonstrate how they weave sacred elements into their music..

On Sunday, the festival will hold Masters of Movement, a conversation about dance traditions with internationally renowned Kathak dancer Farah Yasmeen Shaikh, Native Pride Dancers and Korean Performing Arts Institute of Chicago. Joe Hall & the Cane Cutters, Afro Dominicano, Swanky Kitchen Band, and Cyril Neville will take part in a session titled Caribbean Crossroads: From the Bayou to the Barrio and Jesse Daniel, Lutchinha and Sugaray Rayford will talk and sing songs about love, loss, and trouble in a panel called Songs for Good Times and Hard Times.

"Annually, one of the highlights of the Lowell Folk Festival has been the dazzling array of food options for hungry folk-arts lovers of all ages," said Viliesis. "The 'I'm only here for the food' t-shirts were a big hit last fall, everyone has a favorite food group they come back for every year."

At Boarding House Park, the Dance Pavilion and Market Street, foods from around the world are prepared and served by local non-profits representing the diverse ethnic cultures to be found in New England. Cuisines representing Portuguese, Brazilian, Greek, Polish, Asian, Latin, African, Burmese and so many other communities, promises a rich and diverse culinary and cultural experience.

Festival goers also have the opportunity to experience visual and hand-craft arts at the Experience Lowell Arts Market. It will feature 50 area artists, craft makers, and organizations, enabling festival attendees to experience everything that Mill City's arts and culture community has to offer.

តមកពីទំព័រទី ១៣

## តើវៀតណាមត្រៀមលក្ខណៈគ្រប់

កម្ពុជា និងទទួលសំណូករាប់លានដុល្លារពីអ្នករត់ពន្ធនេះបើយោងតាមរបាយការណ៍ស្តីពីបរិស្ថានរបស់ទីភ្នាក់ងារស៊ើបអង្កេត។

វៀតណាមបានបង្កើតកិច្ចព្រមព្រៀងអភិវឌ្ឍតំបន់ត្រីកោណ កម្ពុជា-ឡាវ-វៀតណាម (CLV-Triangle Area Development) ក្នុងឆ្នាំ១៩៩៩ ដែលពាក់ព័ន្ធនឹងខេត្តចំនួន ១០ ហើយក្រោយមកបានកើនដល់ ១៣ ខេត្ត រវាងប្រទេសទាំងបី និងមានគោលបំណងជំរុញការតភ្ជាប់សេដ្ឋកិច្ចនៅតាមព្រំដែន។ ក្រោមលេសនៃការអភិវឌ្ឍន៍នេះ អ្នកជំនាញកម្ពុជាជាច្រើនបានលើកឡើងពីការព្រួយបារម្ភថា កម្ពុជានឹងបាត់បង់អធិបតេយ្យភាពរបស់ខ្លួន។ ប្រជាជនកម្ពុជាជាច្រើនគិតថាវាជារឿងតូចតាចព្រោះការអភិវឌ្ឍន៍នឹងមានត្រឹមតែខេត្តជាប់ព្រំដែន ប៉ុន្តែពួកគេដឹងតិចតួចថាវៀតណាមមានបំណងចង់ឱ្យជនជាតិវៀតណាមរស់នៅ និងធ្វើការដោយសេរីដោយគ្មានទិដ្ឋាការការជួញដូរដែលគ្រប់គ្រងដោយវៀតណាម សាលារៀនបង្រៀនភាសា និងវប្បធម៌វៀតណាម និងលើកកម្ពស់ទំនាក់ទំនងមិត្តភាពជាមួយវៀតណាម ទូទាំងព្រះរាជាណាចក្រ កម្ពុជា និងឡាវ។

ថ្មីៗនេះ វៀតណាមបានសាងសង់អគាររដ្ឋសភាថ្មីនៅកម្ពុជា ដែលមានតម្លៃ ២៥ លានដុល្លារ ហើយនឹងបើកដំណើការក្នុងពេលឆាប់ៗនេះ នេះបើយោងតាមការលើកឡើងរបស់លោកស្រី ឃួន សុដារី ប្រធានរដ្ឋសភាកម្ពុជា។ នៅប្រទេសឡាវ វៀតណាមក៏បានសាងសង់អគាររដ្ឋសភាថ្មី ការិយាល័យសភា និងអគារជាច្រើនទៀតសម្រាប់ការអប់រំ និងវប្បធម៌ ដែលមានតម្លៃជិត ៣០០ លានដុល្លារ។ ជាមួយនឹងវេទិកាអន្តរសភានេះ កម្ពុជាមានប្រជាជន ១៧ លាននាក់ ឡាវមាន ៧,៥ លាននាក់ វៀតណាមមាន ៩៨លាននាក់។បើនិយាយពីការបោះឆ្នោត គឺខ្មែរ១ នាក់ទល់នឹងវៀតណាម ៥.៧ នាក់។ វានឹងគ្មានអំណាចសម្រាប់កម្ពុជា

តទៅទំព័រទី២១

# លោក អ៊ុំ សំអាន ទាមទារឱ្យលោក សុខ ឥសាន ចេញមុខសុំទោសពលរដ្ឋខ្មែរក្រោមជាសាធារណៈ

តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ លោក អ៊ុំ សំអាន អះអាងថា អ្នកនាំពាក្យគណបក្សប្រជាជនកម្ពុជា លោក សុខ ឥសាន គឺជាបុគ្គលដែលវង្វេងប្រវត្តិសាស្ត្រជាតិ និងត្រូវសុំទោសពលរដ្ឋខ្មែរក្រោមជាសាធារណៈ បន្ទាប់ពីអ្នកនាំពាក្យរូបនេះថា «ពលរដ្ឋខ្មែរកម្ពុជាក្រោម គឺជាជនជាតិវៀតណាម»។

មន្ត្រីជាន់ខ្ពស់បក្សប្រឆាំងលោក អ៊ុំ សំអាន ប្រាប់សារព័ត៌មាន The Cambodia Daily នៅថ្ងៃទី១៥ កក្កដា នេះថា ពលរដ្ឋខ្មែរក្រោមមានសញ្ជាតិវៀតណាម ប៉ុន្តែពួកគាត់គឺជាជនជាតិខ្មែរ សូម្បីអត្តសញ្ញាណប័ណ្ណដែលចេញដោយអាជ្ញាធរវៀតណាម ក៏ដោយ ក៏បញ្ជាក់ថាពួកគេជាពលរដ្ឋខ្មែរដែរ។

ប្រភពដដែលថា លោក សុខ ឥសាន មិនគួរកើតមកជាជនជាតិខ្មែរទេ សមតែកើតមកជាជនជាតិវៀតណាម ព្រោះថា បើផ្អែកលើប្រវត្តិសាស្ត្រ និងផ្លូវច្បាប់ គឺនៅតែអាចបញ្ជាក់បានថា ពលរដ្ឋខ្មែរក្រោម គឺជាខ្មែរ មិនមែនវៀតណាមដាច់ខាត។


លោក សុខ ឥសាន អ្នកនាំពាក្យគណបក្សប្រជាជនកម្ពុជា

លោក អ៊ុំ សំអាន បញ្ជាក់ថា ការអះអាងរបស់លោក សុខ ឥសាន ក៏មានមូលហេតុផ្សេងដែរព្រោះគណបក្សប្រជាជនកម្ពុជា ត្រូវបានបង្កើតឡើងដោយវៀតណាម ខណៈលោក ហ៊ុន សែន ក៏ត្រូវលើកបន្តុបដោយវៀតណាម ដែរ ដូច្នេះអ្វីៗដែលពួកគេធ្វើ គឺដើម្បីវៀតណាមទាំងអស់។

លោក សុខ ឥសាន បានអះអាងថា ពលរដ្ឋខ្មែរកម្ពុជាក្រោមទាំងអស់ គឺជាជនជាតិវៀតណាម ចាប់តាំងពីបារាំង ប្រគល់ទឹកដីកូសាំងស៊ីន ឬទឹកដីកម្ពុជាក្រោម ឱ្យវៀតណាម កាលពីឆ្នាំ១៩៤៩ មកនោះ។

លោកថា ពិតមែនតែពលរដ្ឋខ្មែរក្រោមចាត់ទុកខ្លួនឯងថាជាខ្មែរ ប៉ុន្តែអត្តសញ្ញាណប័ណ្ណ និងលិខិតឆ្លងដែនរបស់ពួកគេ បានកំណត់ថាអ្នកទាំងនោះគឺជាជនជាតិវៀតណាម ព្រោះនេះជាគោលការណ៍ច្បាប់។

ជុំវិញបញ្ហានេះ ពលរដ្ឋខ្មែរក្រោមដែលល្បីល្បាញលើបណ្ដាញសង្គមហ្វេសប៊ុកមួយរូបឈ្មោះលោក ថាច់ សាថេន ស្នើឱ្យលោក សុខ ឥសាន ទៅលេងទឹកដីកម្ពុជាក្រោម ដើម្បីស្វែងយល់ឱ្យដឹងច្បាស់ថា តើពលរដ្ឋខ្មែរក្រោមជាជនជាតិវៀតណាម មែនដែរឬក៏អត់។

លោកថា បើផ្លូវច្បាប់កំណត់ថា

តទៅទំព័រទី១៧






## តមកពីទំព័រទី ១៦ លោក អ៊ុំ សំអាន ទាមទារឲ្យលោក

ពលរដ្ឋខ្មែរក្រោមជាជនជាតិវៀតណាម ម្ល៉េះមកដល់ថ្ងៃនេះគ្មានអក្សរខ្មែរតាមវត្តអារាម និងសាលារៀនទេ។ ជាងនេះទៀត ប្រពៃណីខ្មែរក៏បាត់បង់ដែរ ដូច្នេះភស្តុតាងទាំងនេះបង្ហាញថា វៀតណាមនៅតែទទួលស្គាល់ថាពលរដ្ឋខ្មែរក្រោមគឺជាខ្មែរ។

ទាក់ទិននឹងបញ្ហានេះក្នុងព្រះរាជសាររបស់សម្តេចព្រះនរោត្តម សីហនុ កាលពីថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ សរសេរថា ព្រះអង្គសូមគាំទ្រសំណើទាមទារសិទ្ធិមួយចំនួនរបស់ជនជាតិខ្មែរដែលមានដើមកំណើតនៅកម្ពុជាក្រោម ដែលមិនទាន់មានសិទ្ធិទទួលបានអត្តសញ្ញាណប័ណ្ណបណ្ណគ្រួសារការចុះបញ្ជីអត្រានុកូលដ្ឋាន និងលិខិតឆ្លងដែន។ល។

ជាងនេះទៀត សម្តេចព្រះនរោត្តម សីហនុ បានថ្លែងថា ចំពោះខ្មែរទាំងប្រុសទាំងស្រីដែលរស់នៅប្រទេសកម្ពុជា ត្រូវតែបានទទួលស្គាល់ជាខ្មែរពេញលក្ខណៈច្បាប់នៅលើទឹកដីកម្ពុជា ទោះបីជាពួកគេបានយកសញ្ជាតិរបស់បរទេសដែលគេកំពុងនៅក៏ដោយ។

ចំណែកអ្នកវិភាគនយោបាយសង្គម និងជាប្រធានវេទិកាពលរដ្ឋលោក គឹម សុខ លើកឡើងថា ការអះអាងរបស់លោកសុខឥសានគឺបង្ហាញពីការរើសអើង និងប្រមាថលើប្រជាពលរដ្ឋខ្មែរក្រោមយ៉ាងធ្ងន់ធ្ងរ ដែលប្រឆាំងនឹងសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមទាំងស្រុង។ លោកថាខ្មែរក្រោមគឺជាម្ចាស់ទឹកដីកម្ពុជាក្រោម មិនមែនជាជនជាតិភាគតិចដែលរស់នៅលើទឹកដីវៀតណាម ទេ។

នៅឆ្នាំ១៩៤៩ រដ្ឋាភិបាលបារាំងបានសម្រេចកាត់ទឹកដីកូសាំងស៊ីន ឬទឹកដីកម្ពុជាក្រោមឱ្យវៀតណាមគ្រប់គ្រងដោយគ្មានការឯកភាពពីព្រះមហាក្សត្រខ្មែរដែលបន្សល់ទុកឲ្យខ្មែរក្រោមជាច្រើនលាននាក់ដែលជាម្ចាស់ស្រុក រស់នៅលើទឹកដីកំណើតរបស់ខ្លួនក្រោមការគាបសង្កត់របស់វៀតណាមរហូតមកដល់សព្វថ្ងៃនេះ៕

## តមកពីទំព័រទី ១៤ ជំនន់ទឹកភ្លៀងនៅរាជធានីភ្នំពេញ...

បានចេញរបាយការណ៍ ដោយបានលាតត្រដាងពីផលប៉ះពាល់បរិស្ថាន និងសង្គមធ្ងន់ធ្ងរបណ្តាលមកពីការអភិវឌ្ឍទីក្រុងរណប និងបុរីជាច្រើន ដែលបង្កឲ្យមានការលិចលង់នៅក្នុងរាជធានីភ្នំពេញនៅពេលមានភ្លៀងធ្លាក់ គម្រោងទាំងនោះបានចាប់ផ្តើម ដីខ្សាច់លុបបឹងធម្មជាតិ និងតំបន់ដីសើមនៅក្នុងរាជធានីភ្នំពេញចាប់តាំងពីឆ្នាំ២០០៣ រហូតមកសមាគមធាងត្នោត រកឃើញថាបឹងធម្មជាតិចំនួន១៦ ត្រូវបានគេលុបទាំងស្រុង ហើយបឹងចំនួន១០ ទៀត កំពុងតែត្រូវបានគេចាក់លុប ផ្នែកខ្លះនៅក្នុងចំណោមបឹងធម្មជាតិចំនួន២៦ នៅរាជធានីភ្នំពេញចាប់តាំងពីឆ្នាំ១៩៩០ មកនៅក្នុងរយៈពេល ០៥ឆ្នាំ ចុងក្រោយនេះមហាជនកត់សម្គាល់ថាជំនន់ទឹកភ្លៀងកាន់តែមានស្ថានភាពអាក្រក់ជាងមុន ក្រោយពីបឹងតាមោក ឬបឹងកប់ស្រូវ ដែលជាអាងស្តុកទឹកធម្មជាតិដ៏ ធំមួយនៅក្នុងរាជធានីភ្នំពេញ ត្រូវបានអ្នកមានលុយមានអំណាចទាំងនោះអស់ជាច្រើនពាន់ហិកតា មានការបើកភ្លើងខៀវអនុញ្ញាតពីមេដឹកនាំគណបក្សប្រជាជនកម្ពុជា គឺលោក ហ៊ុន សែន៕

## Floods in Phnom Penh Remain a Problem

From Page 14

Phnom Penh always faces flood when rain comes. It happens when development projects have started to putting sand into natural lakes and wetlands in Phnom Penh from 2003 until the Samakum Teang Tnort found that 16 natural lakes have completely wiped out and 10 out of 26 natural lakes are being partially filled with lands.

In Phnom Penh, since 1990, in the last 5 years, the public has noticed that the flooding situation has worsened after Boeung Ta Mok or Boeung Kob Srov, which is one of the largest natural water reservoirs in the capital filled with lands. Leader of the Cambodian People's Party, Mr. Hun Sen.Phnom Penh gave the green light and permis-






# ព្រឹទ្ធសមាជិកសភា ប្រោន (Brown) ព្រមានរដ្ឋបាលថា ការផ្តល់លក្ខខ័ណ្ឌសេដ្ឋកិច្ចទីផ្សារវៀតណាមនឹងគំរាមកំហែង ដល់កម្មករ និងក្រុមហ៊ុនផលិតរដ្ឋ OHIO ចំណេញដល់ប្រទេសចិន

**ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៤**

**សូមអានលិខិតទាំងស្រុងខាងក្រោមនេះ៖**

សូមគោរពរដ្ឋមន្ត្រី Raimondo

យើងសរសេរលិខិតនេះ ដើម្បីបង្ហាញពីកង្វល់សំខាន់ៗរបស់យើងជាមួយនឹងការពិនិត្យឡើងវិញរបស់ក្រសួងពាណិជ្ជកម្ម អំពីស្ថានភាពរបស់ប្រទេសវៀតណាមជាសេដ្ឋកិច្ចមិនទីផ្សារ (NME) ក្រោមច្បាប់ពាណិជ្ជកម្មរបស់សហរដ្ឋអាមេរិក។ មានភ័ស្តុតាងច្រើនក្រៃលែងដែលបង្ហាញថា វៀតណាមមិនបំពេញតាមលក្ខខណ្ឌច្បាប់ដែលបង្កើតឡើងដោយសភាដើម្បីទទួលបានឋានៈសេដ្ឋកិច្ចទីផ្សារ។ យើងមានការព្រួយបារម្ភជាពិសេសចំពោះរបាយការណ៍ដែលក្រសួងពាណិជ្ជកម្មបានសន្យាជាមួយរដ្ឋាភិបាលនៃប្រទេសវៀតណាមថា ការត្រួតពិនិត្យរបស់ទីភ្នាក់ងាររបស់លោកនឹងនាំឱ្យមានការប្តេជ្ញាចិត្តដ៏អំណោយផលដល់ការបំផ្លាញឧស្សាហកម្ម និងកម្មកររបស់សហរដ្ឋអាមេរិក។[1] យើងជំរុញឱ្យក្រសួងពាណិជ្ជកម្ម ពិនិត្យមើលភស្តុតាង ជាច្រើនឲ្យបានពេញលេញ នៅពេលក្រសួងធ្វើការត្រួតពិនិត្យរបស់ខ្លួន និងដើម្បីពិចារណាពីផលប៉ះពាល់លើការងារ និងផលិតករអាមេរិក ក្នុងការសម្រេចចុងក្រោយរបស់ខ្លួន។

